ព្រឹត្តិបត្រ ខុមហ្វ្រែល

# អ្នកឃ្លាំមើល

The OBSERVER Bulletin

ខុមហ្វ្រែល COMFREL

លេខ ៤៧/ឆ្នាំទី១៣ ចេញផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២





## យុត្តិធម៌ក្នុងការបោះឆ្នោតដរាបណាការប្រកួតប្រជែងប្រកបដោយសមភាព និងសុចរិតភាព

### មាតិកា


**ការពង្រឹងយុត្តធម៌នៃដំណើរការបោះឆ្នោតនៅកម្ពុជាឆ្នាំ២០១២ និង២០១៣ ១**

»»ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ ២ »»ការប្រើប្រាស់ធនធានរដ្ឋបំរើឱ្យគណបក្សនយោបាយ... ៣

»»ការជ្រើសរើសអ្នកសង្កេតការណ៍ស្មគ្រចិត្ត និងឯករាជ្យ ឆ្នាំ២០១២ ១២

»»ឃ្លាំមើល សភា និងតំណាងរាស្ត្រ ៩



*អ្នកឃ្លាំមើល ៖ ការផ្សាយរបស់ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា*

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២

LICADHO CHRAC ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា Cambodian Defenders Project ខុមហ្វ្រែល COMFREL និកហ្វិច NICFEC

រូបសញ្ញាសម្គាល់ (Logos) អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍រួម

# សេចក្តីថ្លែងការណ៍រួម

## ការពង្រឹងយុត្តធម៌នៃដំណើរការបោះឆ្នោតនៅកម្ពុជាឆ្នាំ២០១២ និង២០១៣

**យើង**ខ្ញុំទាំងអស់គ្នាជាតំណាងអង្គការសង្គមស៊ីវិល សមាគមមិនមែនរដ្ឋាភិបាលដែលធ្វើការតាមដានស្ថានភាពនយោបាយ និងការបោះឆ្នោតនៅកម្ពុជា (*រួមមាន ១-**សមាគមអាដហុក** ២-**អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស-លីកាដូ** ៣-**គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា** ៤-**អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា** ៥-**អង្គការខុមហ្វ្រែល** ៦-**អង្គការនិកហ្វិច** ៧-**មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍ និងសន្តិភាព** ៨-**សមាគមយុវជនខ្មែរ** ៩-**អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ***) យល់ឃើញថា មកដល់រយៈពេលនេះសេរីភាព និងយុត្តិធម៌ក្នុងការបោះឆ្នោតនៅតែចោទជាបញ្ហា ដោយសារតែការរឹតត្បិតសេរីភាពនៃការប្រកួតប្រជែង ការប្រើប្រាស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធមិនស្របច្បាប់ និងអសមធម៌ក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងការធ្វើសកម្មភាពគាំទ្រ និងប្រឆាំងគណបក្សនយោបាយ។ ការប្រកួតប្រជែងប្រជាធិបតេយ្យ ទោះបីកម្ពុជាប្រកាន់យកប្រព័ន្ធនយោបាយសេរីពហុបក្ស ប៉ុន្តែប្រព័ន្ធនេះមិនទាន់បានអភិវឌ្ឍន៍ទៅរកការប្រកួតប្រជែងពិតប្រាកដនៅឡើយទេ។ ការប្រកួតប្រជែងនយោបាយនៅតែបានចង្អុលបង្ហាញចរិតលក្ខណៈដោយទីលានប្រកួតប្រជែងមិនស្មើគ្នាដដែល ដោយសារតែវានៅតែស្ថិតនៅក្រោមការត្រួតត្រារបស់គណបក្សកាន់អំណាច។ លើសពីនេះទៀត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងធនធានរបស់រដ្ឋ បានបើកដៃឱ្យគណបក្សប្រជាជនកម្ពុជា ទទួលយកប្រយោជន៍ដោយប្រៀបក្នុងការប្រកួតប្រជែង ដែលមិនអនុញ្ញាតឱ្យគណបក្សដទៃមានចន្លោះក្នុងការចូលរួមពេញលេញ។

នៅក្នុងខែមិថុនា ឆ្នាំ២០១២ ឆាប់ៗខាងមុខនេះ នឹងមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ហើយក្នុងខែកក្កដា ឆ្នាំ២០១៣ នឹងមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥។ លោក **ធន សារាយ ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល** និងជាប្រធានអង្គការសិទ្ធិមនុស្សអាដហុក បានស្នើឱ្យរាជរដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវធានាការបំពេញភារកិច្ច និងការទទួលខុសត្រូវដើម្បីធ្វើឱ្យការបោះឆ្នោតដោយយុត្តិធម៌ និងសុចរិតភាព។

ដំណើរការបោះឆ្នោត ទីលានប្រកួតប្រជែងតាមបែបប្រជាធិបតេយ្យ នៅតែរងការរឹតត្បិត ជាពិសេសសេរីភាព និងការបញ្ចេញមតិ និងការប្រមូលផ្តុំ។ ស្ថាប័ននីតិប្រតិបត្តិ និងគណបក្សប្រជាជនកម្ពុជា នៅតែបន្តត្រួតត្រាសាខាដទៃទៀតរបស់រដ្ឋាភិបាល នាំឱ្យស្ថាប័នរដ្ឋនានា និងស្ថាប័នតុលាការ ខ្វះខាតឯករាជភាព និងអំណាចដើម្បីដើរតួនាទី ត្រួតពិនិត្យ និងតុល្យភាពនៃអំណាចនីតិប្រតិបត្តិ។ ឥទ្ធិពលអវិជ្ជមានទាំងនេះ ប៉ះពាល់ដល់ទីលានប្រកួតប្រជែងនយោបាយ និងការបំបិទសេរីភាពបញ្ចេញមតិនយោបាយទាក់ទងនឹងបញ្ហាសំខាន់ៗសម្រាប់ជាតិ និងអន្តរជាតិ។ មានពន្លឺតិចតួច ក្នុងការផ្តល់ឱកាសដល់ប្រធានគណបក្សប្រឆាំងសមរង្ស៊ី ដើម្បីចូលរួមប្រកួតប្រជែងពេញលេញជាមួយគណបក្សកាន់អំណាច។ លោក **សុក សំអឿន នាយកប្រតិបត្តិនៃអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា** បានមានប្រសាសន៍ថា "*ករណីបទល្មើសរបស់ ឯកឧត្តម សម រង្ស៊ី មិនមានទុចរិតភាពធ្ងន់ធ្ងរដល់សង្គមទេ វាគ្រាន់តែទាក់ទិននឹងសកម្មភាពបញ្ចេញមតិខាងនយោបាយប៉ុណ្ណោះ*"។

តទៅទំព័រ ៩

# ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ

*ដកស្រង់ចេញពីរបាយការណ៍ឆ្នាំ២០១១ របស់ ខុមហ្វ្រែល ស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងការកំណែទម្រង់ នៅកម្ពុជា*



របាយការណ៍នេះអាចស្វែងរកបាន: www.comfrel.org

ជាប្រទេសហត្ថលេខីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយបានប្តេជ្ញាចិត្តគាំទ្រសេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស ដោយប្បញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ប្រទេសកម្ពុជាមានកាតព្វកិច្ចរៀបចំការបោះឆ្នោតតាមបែបប្រជាធិបតេយ្យពិតប្រាកដ ដើម្បីកំណត់អំណាចនយោបាយ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា *"ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុយ៉ាងតិច១៨ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ* ។ បទប្បញ្ញត្តិទាំងនេះ រឹតបណ្តឹងសិទ្ធិបោះឆ្នោត និងសិទ្ធិដើម្បីឈរឈ្មោះឱ្យគេបោះឆ្នោត នឹងកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (មាត្រា ៣៤-ថ្មី) បានចែងថា *"គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៖ ១-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបព្វជិតសាសនា ឬ ២-ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ ៣-ជនដែលត្រូវបាន ផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬ ៤-ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ ៥-ជនដែលត្រូវដកហូរជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ ៦-សមាជិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬ៧-សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ៨-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ"* ។ ជាងនេះទៅទៀត សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា២១) បានចែងថា *"មនុស្សគ្រប់រូបមានសិទ្ធិដើម្បីចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួន ដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី។ (....) ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ។ ឆន្ទៈនេះត្រូវ សម្តែងចេញតាមរយៈការបោះឆ្នោតយ៉ាងទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដមាន លក្ខណៈសកលស្មើភាព និងបោះឆ្នោតដោយសម្ងាត់ ឬតាមនីតិវិធីសមមូលដែលធានាសេរីភាពនៃការបោះឆ្នោត។"* ហើយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ-បាយ (មាត្រា ២៥) បានចែងថា *"ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាស រួមចំណែកដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងដែលខ្លួនជ្រើសរើសដោយសេរី។ បោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដតាមកាលកំណត់ទៀតទាត់ ជាសកល ស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត។"*

ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ អាចត្រូវបានយល់ជា ធាតុមួយពិតប្រាកដនៃដំណើរការប្រជាធិបតេយ្យនៅកម្ពុជា។ ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ អនុញ្ញាតឱ្យអ្នកបោះឆ្នោតជ្រើសរើសដោយសមភាព និងសេរី ក្នុងចំណោមកម្មវិធីនយោបាយ និងបេក្ខជន ដែលត្រូវបានផ្តល់ដោយ ការប្រកួតប្រជែងគណ-បក្សនយោបាយយ៉ាងតិចពីរ ក្នុងការបោះ-ឆ្នោតប្រកួតប្រជែងសម្រាប់មន្ត្រីរដ្ឋាភិបាលសាធារណៈ។ តាំងពីឆ្នាំ២០១១ គ្មានការបោះឆ្នោត ដែលបានប្រាព្ធឡើង លើកលែងតែការបោះឆ្នោតមួយនៅរាជធានីភ្នំពេញ នៅក្នុងកម្រិតសង្កាត់ (*ការបោះឆ្នោតដើម្បីជ្រើសរើសក្រុមប្រឹក្សាសង្កាត់ពោធិសែនជ័យ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ ២០១១ ដែលជាសង្កាត់បង្កើតថ្មីនៅរាជធានីភ្នំពេញ។ គណបក្សប្រជាជនកម្ពុជាទទួលបាន ១៥ អាសនៈ និងគណបក្សសមរង្ស៊ី ទទួលបាន ៤ អាសនៈ ហើយគ្មានរបាយការណ៍ពីភាពមិនប្រក្រតី*)។

ខុមហ្វ្រែល រកឃើញថា កំណែទម្រង់មួយចំនួន ទាមទារឱ្យមាននៅក្នុងឆ្នាំ ២០១១ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងឆ្នាំ២០១២

តទៅទំព័រ ៤



រូបភាព ៖ ស្រី សុភ័ក្រ្ត

១៤-ឧសភា-២០១២ ៖ ខុមហ្វ្រែល ដឹកនាំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍សង្កេតការប្រើប្រាស់ធនធានរដ្ឋមប្រើគណបក្សនយោបាយ នៅភោជនីយដ្ឋានខ្មែរសុរិន្ទ

# របាយការណ៍សង្ខេប

## ការប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យគណបក្សនយោបាយ

## ការសង្កេតប្រព័ន្ធផ្សព្វផ្សាយ

## លទ្ធផលបឋមនៃការសង្កេតបរិយាកាសការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ ឆ្នាំ២០១២

### ការប្រើប្រាស់ធនធានរដ្ឋដើម្បីគណបក្សនយោបាយ

មានការរំលោភ ឬបំពានក្នុងការប្រើប្រាស់ធនធានរដ្ឋទាំងសម្ភារៈ។ មន្ត្រីរាជការ ព្រមទាំងអាជ្ញាធរ និងកងកម្លាំងប្រដាប់អាវុធបានធ្វើសកម្មភាពបំរើគណបក្សកាន់អំណាច ពិសេសគណបក្សប្រជាជនកម្ពុជា ហើយគណបក្សប្រជាជនកម្ពុជាក៏បានរៀបចំរចនាសម្ព័ន្ធចេញពីមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋបាលសាធារណៈ និងកងកម្លាំងប្រដាប់អាវុធ។ នេះបញ្ជាក់ថាទាំងមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងគណបក្សកាន់អំណាចបានធ្វើសកម្មភាពមិនស្របច្បាប់គណបក្សនយោបាយ និងច្បាប់ផ្សេងទៀត ។

តាមរយៈការសង្កេតរបស់ ខុមហ្វ្រែល រកឃើញថាសកម្មភាពមិនស្របច្បាប់នេះមានលក្ខណៈជាប្រព័ន្ធ និងដោយគ្មានយន្តការត្រួតពិនិត្យ ហើយធ្វើឲ្យមន្ត្រីជាន់ខ្ពស់ក្នុងរដ្ឋបាលស៊ីវិល និងកងកម្លាំងប្រដាប់អាវុធមិនមានរូបភាព "*អព្យាក្រិត្យឥតលម្អៀង*"។ ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋក៏ត្រូវបានប្រើប្រាស់ដោយលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជា។ គណបក្សប្រជាជនកម្ពុជាបានប្រើប្រាស់ទីលានសាធារណៈច្រើន ដោយលើកផ្ទាំងរូបធំតូចជាច្រើន ប៉ុន្តែគណបក្សផ្សេងទៀតត្រូវបានរារាំងដោយការលើកស្លាកនៅទីលានសាធារណៈនោះ ។

មានករណីមិនស្របច្បាប់ជាក់ស្តែងដូចជា៖

**១. ការបង្កើតជាប្រព័ន្ធនូវតួនាទីបក្សក្នុងជួរមន្ត្រីរាជការ**

គណបក្សប្រជាជនកម្ពុជាបានបង្កើតតួនាទីជាប្រព័ន្ធក្នុងជួរមន្ត្រីជាន់ខ្ពស់របស់រដ្ឋបាលស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដោយក្នុងនោះភាគច្រើនមន្ត្រីដែលមានតួនាទីជាអភិបាលខេត្ត អភិបាលក្រុង/ស្រុក បានកាន់តួនាទីជាប្រធានគណបក្សប្រជាជនកម្ពុជាប្រចាំខេត្ត និងក្រុង/ស្រុក។ មន្ត្រីដែលមានតួនាទីជាអភិបាលរងខេត្ត អភិបាលរង ក្រុង/ស្រុក ភាគច្រើនកាន់តួនាទីជាអនុប្រធានគណបក្សប្រជាជនកម្ពុជាខេត្ត ក្រុង/ស្រុក។ ជាពិសេសទៅទៀតគណបក្សប្រជាជនកម្ពុជាបានបង្កើតតួនាទីក្នុងបក្សដូចជា ប្រធាន/អនុប្រធានគណៈពង្រឹងមូលដ្ឋានស្រុក/ក្រុង/ឃុំ ដោយដាក់មន្ត្រីរាជការចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានរហូតដល់ថ្នាក់អគ្គលេខាធិការ អគ្គនាយក ចំណែកកងកម្លាំងប្រដាប់អាវុធខ្លះមានតួនាទីក្នុងគណបក្សប្រជាជនកម្ពុជា ដូចជាស្នងការនគរបាលខេត្ត ជាប្រធានគណៈពង្រឹងស្រុក ឬសមាជិកគណៈអចិន្ត្រៃយ៍របស់គណបក្ស។ បើយោងតាម**មាត្រាទី១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ** *បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិអាចចូលរួមជាសមាជិក គណបក្សនយោបាយនានាបានតែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ។ គណបក្សនយោបាយមិនត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងក្នុងស្ថាប័ន សាសនា តុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិទេ។* និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល *មាត្រាទី ៣៧ មន្ត្រីរាជការត្រូវមានអព្យាក្រឹត្យភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបំរើសកម្មភាពនយោបាយ ១/ ធ្វើការដើម្បីផលប្រយោជន៍បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ២/ធ្វើការដើម្បីផលប្រយោជន៍ គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។*

តទៅទំព័រ ៦

*(ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ)...*

និង២០១៣ ដែលនឹងមកដល់។ កំណែទម្រង់សំខាន់ៗទាំងនោះ រាប់បញ្ចូល (១). ការផ្លាស់ប្តូរនៃសមាសភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងគណៈកម្មការបោះឆ្នោតថ្នាក់ក្រោមបង្គាប់កម្រិតថ្នាក់ខេត្ត សង្កាត់ និងមូលដ្ឋាន (២). ការបង្កើនអាសនៈរបស់សមាជិករដ្ឋសភាដោយសារតែការកើនឡើងនៃទំហំប្រជាពលរដ្ឋក្នុងមណ្ឌលបោះឆ្នោតជាច្រើន (៣). កំណែទម្រង់នៃរបបបោះឆ្នោតសម្រាប់ជ្រើសតាំងសមាជិកព្រឹទ្ធសភា ឆ្ពោះទៅរកការបោះឆ្នោតដែលមានលក្ខណៈប្រកួតប្រជែងមួយ និងផ្លាស់ប្តូរពីច្បាប់បោះឆ្នោតឆ្ពោះទៅរកក្របខណ្ឌច្បាប់ដែលជាប់ទាក់ទងគ្នា រាប់បញ្ចូលនីតិវិធីដ៏ប្រសើរសម្រាប់ដោះស្រាយបណ្តឹងបោះឆ្នោត។ ពេលមិនមានកំណែទម្រង់ទាំងនេះ គ.ជ.ប នៅតែបន្តកង្វះខាតជំនឿចិត្តក្នុងចំណោមភាគីពាក់ព័ន្ធនឹងនយោបាយផ្សេងទៀត ខណៈ ចំនួនអាសនៈនៃរដ្ឋសភាបច្ចុប្បន្ន បន្តដាក់គោលការណ៍នៃសិទ្ធិបោះឆ្នោតសមភាពសកលនៅក្នុងបញ្ហា។ ជាងនេះទៀត ច្បាប់បោះឆ្នោតនៅតែស្មុគស្មាញ ហើយខ្វះយន្តការដោះស្រាយបណ្តឹងប្រកបដោយប្រសិទ្ធិភាព។ ទោះបីជាយ៉ាងនេះក៏ដោយ មានការប្រែប្រួលជាវិជ្ជមានខ្លះដែរក្នុងឆ្នាំ២០១១ ដោយមានការកំណែទម្រង់ការចុះឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ ដែលដឹកនាំដល់ ការធ្វើឱ្យប្រសើរឡើងនៅក្នុងការប្រតិបត្តិការណ៍ចុះឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ ដោយសារបញ្ហាបច្ចេកទេស និងការចោទប្រកាន់ច្រើនពេកថា ការចុះឈ្មោះត្រូវបានប្រើប្រាស់ខុសសម្រាប់ឃោសនាបោះឆ្នោត ហើយដឹកនាំដល់ការបាត់បង់សិទ្ធិអ្នកបោះឆ្នោតជាច្រើន បានបន្តបង្ហាញកំសោយនៃប្រព័ន្ធចុះឈ្មោះបោះឆ្នោតបច្ចុប្បន្ន។

## កំណែទម្រង់ការបោះឆ្នោត

គណបក្សនយោបាយក្រៅពីគណបក្សប្រជាជនកម្ពុជាបានបន្តក្នុងឆ្នាំ២០១១ ដើម្បីទាមទារកំណែទម្រង់ គ.ជ.ប។ គ.ជ.ប និងគណៈកម្មការបោះឆ្នោតថ្នាក់ខេត្ត និងឃុំ/សង្កាត់ ក្រោមបង្គាប់របស់ខ្លួន បានដឹងថា ខ្វះឯកភាព និងអព្យាក្រឹត្យភាព ពីព្រោះគណបក្សប្រជាជនកម្ពុជា ត្រួតត្រាក្នុងរដ្ឋបាលប្រទេស។ ក្នុងអតីតកាល គណៈកម្មាធិការបោះឆ្នោត ត្រូវបានបង្កើតឡើងពីសមាជិកនៃគ្រប់គណបក្សនយោ-បាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភានីតិកាលចុងក្រោយ។ ប៉ុន្តែ រូបមន្តនេះបានផ្លាស់ប្តូរនៅមុនពេលការបោះឆ្នោតរដ្ឋសភាឆ្នាំ២០០៣ ដើម្បីបង្កើនភាពមិនលម្អៀងនៃគណៈកម្មាធិការបោះឆ្នោត ក្រោយជម្លោះរវាងតំណាងគណបក្សនយោបាយក្នុងគណៈកម្មាធិការបោះឆ្នោត ដែលបានកើតមាននៅក្នុងពេលដំណើរការបោះឆ្នោតរដ្ឋសភាឆ្នាំ១៩៩៨។ តាមវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ គ.ជ.ប ជា *"ស្ថាប័នឯករាជ្យនិងអព្យាក្រឹត្យ"* ហើយគណៈកម្មាធិការបោះឆ្នោតនៅគ្រប់កម្រិតត្រូវតែអព្យាក្រឹត្យមិនលម្អៀង នៅក្នុងការអនុវត្តកាតព្វកិច្ចរបស់ពួកគេ។ ប៉ុន្តែប្បញ្ញត្តិមួយនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ បានចែងថា មន្ត្រីបោះឆ្នោតត្រូវសុំលាឈប់ជាបណ្តោះអាសន្នពីមុខងារគណបក្សរបស់ពួកគេ រហូតដល់ផុតអាណត្តិរបស់ពួកគេ ហើយមន្ត្រីបោះឆ្នោតត្រូវជ្រើសរើសដោយក្រសួងមហាផ្ទៃ គណៈរដ្ឋមន្ត្រី និងរដ្ឋសភា។ តាំងពីស្ថាប័នទាំងនោះត្រួតត្រាដោយគណបក្សប្រជាជនកម្ពុជា ក្រោយការបោះឆ្នោតឆ្នាំ២០០៨ ប្បញ្ញត្តិទាំងនោះមិនបានបន្ថយមន្ទិលសង្ស័យក្នុងចំណោមគណបក្សនយោបាយផ្សេងពីគណបក្សប្រជាជនកម្ពុជាថា មន្ត្រីបោះឆ្នោតមិនមានអព្យាក្រឹត្យនិងឯករាជ្យពិតប្រាកដ។

ទោះបីជាសមាមាត្រកម្រិតជាតិត្រូវបានធ្វើឡើងស្របតាមប្បញ្ញត្តិច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានន័យថា គ.ជ.ប មានសមាសភាព ៥រូប មកពីគណបក្សប្រជាជនកម្ពុជា ២រូប មកពីគណបក្សហ៊្វុនស៊ិនប៉ិច និង ២រូប មកពីគណបក្សសមរង្ស៊ី។ នៅកម្រិតថ្នាក់ខេត្ត ឃុំ សង្កាត់ និងមូលដ្ឋាន ប្រព័ន្ធសមាមាត្រនេះមិនទាន់បានយកទៅអនុវត្តទេ។ គណបក្សនយោបាយដទៃទៀតផ្សេងពីគណ-បក្សប្រជាជនកម្ពុជា នៅបន្តផ្តល់អនុសាសន៍ក្នុងឆ្នាំ២០១១ ដើម្បីណែនាំភាព...

(*តទៅទំព័រ ១៣*)




រូបថ្លុក ខុមប្រៀល បរិយាយអព្យាក្រឹត និងឯករាជភាពរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

យើងខ្ញុំទាំងអស់គ្នា សូមធ្វើការអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធដូចជា ព្រះមហាក្សត្រ រដ្ឋសភា រាជរដ្ឋាភិបាល... មេត្តារិះរកការសម្របសម្រួលខាងនយោបាយណាមួយដែលអាចផ្ដល់ឱកាសដល់លោក សម រង្ស៊ី មេដឹកនាំគណបក្សសម-រង្ស៊ី អាចវិលត្រឡប់មកក្នុងប្រទេស និងបង្កឱ្យមានបរិយាកាសប្រកួតប្រជែងការបោះឆ្នោតមួយប្រកបទៅដោយភាពស្មើគ្នា រវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង។

គណបក្សប្រជាជនកម្ពុជា និងអ្នកនយោបាយរបស់ខ្លួនបានប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋជាលក្ខណៈប្រព័ន្ធ ពិសេសមន្ត្រីរាជការស៊ីវិល នគបាល កងកម្លាំងប្រដាប់អាវុធ កងយោធពលខេមរភូមិន្ទ ដើម្បីធ្វើសកម្មភាពគាំទ្រគណបក្សខ្លួន និងប្រឆាំងគណបក្សផ្សេងៗ។ សកម្មភាពទាំងនេះមាននៅក្នុងរចនាសម្ព័ន្ធចេញពីមន្ត្រីជាន់ខ្ពស់ក្នុងស្ថាប័នរដ្ឋបាលស៊ីវិល និងកងកម្លាំងប្រដាប់អាវុធនានា។ សកម្មភាពគណបក្សកាន់អំណាច និងមន្ត្រីទាំងនោះបានរំលោភច្បាប់គណបក្សនយោបាយ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធ-ពលខេមរភូមិន្ទ ក្រមសីលធម៌នគបាលជាតិ... ។ល។ ស្ថាប័នរដ្ឋបាលសាធារណៈ កងកម្លាំងប្រដាប់អាវុធ ដោយឡែកមន្ត្រីជាន់ខ្ពស់ទាំងនោះ បានបាត់បង់រូបភាព "***អព្យាក្រឹត្យឥតលម្អៀង***"។ ការរំលោភនេះ ធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំងមកលើបរិយាកាសនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ជាពិសេសការប្រកួតប្រជែងឃោសនាបោះឆ្នោតមិនមានភាពស្មើគ្នា។ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធត្រូវរក្សារូបភាពអព្យាក្រឹត្យឥតលម្អៀង និងបញ្ឈប់ការមិនគោរពច្បាប់ទាក់ទិននឹងការធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ។

គ.ជ.ប ត្រូវត្រួតពិនិត្យការប្រើប្រាស់ធនធានរដ្ឋដោយខុសច្បាប់ពីសំណាក់អ្នកនយោបាយ ឬគណបក្សនយោបាយក្នុងអំឡុងពេលបោះឆ្នោត។ គ.ជ.ប គួរតែប្រើអំណាចរបស់ខ្លួនដើម្បីដាក់ទណ្ឌកម្មទៅលើគណបក្សនយោបាយ ឬអ្នកនយោបាយណាដែលបានប្រើប្រាស់ធនធានរដ្ឋខុសច្បាប់។ គ.ជ.ប និងអាជ្ញាធរ ត្រូវធានាថា ទីកន្លែងសាធារណៈ គណ-បក្សនយោបាយចូលរួមប្រកួតបោះឆ្នោតមានសិទ្ធិប្រើប្រាស់ស្មើៗគ្នា។

ដូចគ្នាផងដែរ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានមើលឃើញថា ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងរដ្ឋ និងឯកជន បានផ្សព្វផ្សាយច្រើនក្នុងលក្ខណៈវិជ្ជមាន ឬលើកសរសើរដល់គណបក្សប្រជាជនកម្ពុជា និងរិះគន់ទៅលើគណបក្សប្រឆាំង ដែលនេះជាការបង្ហាញឱ្យឃើញការផ្សព្វផ្សាយលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជាយ៉ាងខ្លាំង។ គណបក្សប្រឆាំង ឬគណបក្សមិនមានអាសនៈក្នុងរដ្ឋាភិបាល មិនអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទាំងនោះទេ ព្រោះប្រព័ន្ធផ្សព្វ-ផ្សាយនេះ មានសម្ព័ន្ធភាព ឬក្រោមការគ្រប់គ្រងផ្ទាល់ដោយគណបក្សប្រជាជនកម្ពុជា។ ប្រព័ន្ធវិទ្យុ និងទូរទស្សន៍ គួរតែរក្សាចន្លោះសម្រាប់ប្រយោជន៍សាធារណៈ និងសមធម៌ក្នុងការប្រើប្រាស់សម្រាប់ប្រយោជន៍គណបក្សនយោបាយ និងផ្ដល់ព័ត៌មានអំពីជម្រើសគោលនយោបាយគណបក្សប្រកួតប្រជែងទៅអ្នកបោះឆ្នោត។

លោកស្រីវេជ្ជបណ្ឌិត **ពុង ឈីវកេក ប្រធានគណៈកម្មាធិការនាយក និចហ្វិក** និងជាប្រធានអង្គការលីកាដូ បានផ្ដល់អនុសាសន៍ថា "*ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីសកម្មភាពឃោសនាបោះឆ្នោតត្រូវធានាឱ្យបានស្មើភាពគ្នា ដោយប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ និងវិទ្យុទាំងឯកជន និងរដ្ឋ*"។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ត្រូវធានាថា វិទ្យុ ទូរទស្សន៍ ផ្ដល់លទ្ធភាពដល់គណបក្សនយោ-បាយមានសម្លេងស្របតាមគោលការណ៍សមធម៌ ក្នុងអំឡុងពេលប្រតិទិនបោះឆ្នោតរបស់ គ.ជ.ប ព្រមទាំងធានាថា ប្រព័ន្ធផ្សព្វផ្សាយឯកជនមិនល្មើសច្បាប់បោះឆ្នោត។ គ.ជ.ប ត្រូវកំណត់ និងបែងចែកម៉ោងផ្សព្វផ្សាយឱ្យបានស្មើៗគ្នាគ្រប់ការឃោសនារបស់គណបក្សនយោបាយនិមួយៗ។

ជាសរុប យើងខ្ញុំទាំងអស់គ្នាយល់ឃើញថា ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ខាងមុខ មានការធាក់ថយយ៉ាងខ្លាំង បើសិនបញ្ហាខាងលើរួមមាន វត្តមានមេដឹកនាំគណបក្សប្រឆាំង ប្រព័ន្ធផ្សព្វផ្សាយ និងការប្រើប្រាស់ធនធានរដ្ឋពិសេសមន្ត្រីរាជការ មិនត្រូវបានយកចិត្តទុកដាក់ដោះស្រាយ ឬកែលម្អ ដោយអនុលោមទៅតាមបទដ្ឋានប្រជាធិបតេយ្យ៕

# ការប្រើប្រាស់ធនធានរដ្ឋបម្រើឲ្យគណបក្សនយោបាយ




រូបថ្លុក របស់ខុមហ្វ្រែល បរិយាយពី ការឃោសនាបោះឆ្នោត និងអព្យាក្រឹតភាពរបស់មន្ត្រីប៉ូលិស

## ២. ការប្រើប្រាស់ទីកន្លែងសាធារណៈ

ការប្រើប្រាស់ទីកន្លែងសាធារណៈ មិនធានាបាននូវភាពស្មើគ្នារវាងគណបក្សកាន់អំណាច និងគណបក្សមិនកាន់អំណាច។ គណបក្សកាន់អំណាចមានលទ្ធភាពច្រើនក្នុងការបង្ហាញនូវស្លាកសញ្ញារបស់ខ្លួន នៅតាមទីសាធារណៈ ជាពិសេសនៅតាមតំបន់នៃទីប្រជុំជន និងផ្លូវជាតិធំៗមួយចំនួន ខណៈដែលគណបក្សមិនកាន់អំណាចផ្សេងទៀតប្រឈមនឹងការគំរាមកំហែងរារាំងក្នុងការលើកផ្លាកសញ្ញា និងផ្ទាំងរូបមេដឹកនាំរបស់ខ្លួនធំៗ។ ទាំងនេះក៏បង្ហាញពីការប្រើប្រាស់ធនធានផ្សេងៗរបស់រដ្ឋសូម្បីតែទីសាធារណៈក៏នៅតែមានភាពមិនស្មើគ្នាដែរ។ ឧទាហរណ៍ដូចជានៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ គណបក្សសមរង្ស៊ីបានលើកស្លាកសញ្ញាគណ-បក្សទៅដាក់លើដីមួយកន្លែងទល់មុខសាលាខេត្តប៉ៃលិន កៀកនឹងស្លាកគណបក្សប្រជាជនកម្ពុជា តែត្រូវប៉ូលីសចុះទៅទម្លាក់ និងរឹបអូសយកស្លាកនោះ។ ករណីនេះត្រូវបានគណបក្សសមរង្ស៊ីចោទប្រកាន់ថា អាជ្ញាធរមានភាពលម្អៀងទៅគណបក្សប្រជាជនកម្ពុជា។

## ៣. ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ

ខុមហ្វ្រែលបានធ្វើការសង្កេតប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ និងឯកជនពីខែកញ្ញា ឆ្នាំ២០១១ ដល់ខែមករា ២០១២។ ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ បានធ្វើការផ្សព្វផ្សាយលម្អៀងទៅគណបក្សប្រជាជនកម្ពុជាដែលបានបង្ហាញពីសកម្មភាពរបស់គណបក្សប្រជាជនកម្ពុជា ដូចជាការចែកអំណោយរបស់គណបក្សនេះ ខណៈដែលមានការផ្សាយពីគណបក្សប្រឆាំងដទៃទៀតអំពីមតិរបស់ពួកគេតិចតួច តាមរយៈប្រជុំសភា និងកម្មវិធីសមធម៌។

ការសង្កេតរបស់ខុមហ្វ្រែលចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១១ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១២ បានបង្ហាញថា ការប្រើប្រាស់ធនធានរដ្ឋ រួមមានទាំងធនធានសម្ភារៈ និងធនធានមនុស្ស មាន ២០០ករណី។ នៅក្នុងនោះក៏បានសង្កេតឃើញថា មាន ៦០%(១២០ករណី) បានកើតឡើងនៅថ្ងៃធ្វើការដែលមន្ត្រីរដ្ឋបាលសាធារណៈចូលរួមក្នុងសកម្មភាពគណបក្សដូចជា ការប្រជុំគណ-បក្ស ការចែកអំណោយ ការឃោសនានិងកម្មវិធីផ្សេងៗទៀតរបស់គណបក្ស។

## ៤. ការប្រើប្រាស់សម្ភារៈ យានយន្ត និងអគាររបស់រដ្ឋ

ខុមហ្វ្រែលបានសង្កេតឃើញថាមាន ២០០ករណី ដែលសុទ្ធតែមានការចូលរួមពី បុគ្គលិកមន្ត្រីរាជការ/មន្ត្រីរដ្ឋ-បាលសាធារណៈ/កងកម្លាំងប្រដាប់អាវុធ ចូលរួមក្នុងសកម្មភាពរបស់គណបក្សប្រជាជនកម្ពុជា។ នៅក្នុងនោះដែរមាន ៣ករណី(១,៥%) ដែលអគាររបស់រដ្ឋមានបិទស្លាកសញ្ញារបស់គណបក្សប្រជាជនកម្ពុជា។ ១០ករណី(៥%) គណបក្សប្រជាជនកម្ពុជាបានប្រើប្រាស់ទីធ្លា/បរិវេណ/អាគាររដ្ឋបំរើឲ្យសកម្មភាពរបស់ខ្លួន។ និង៣ករណី (១,៥%) កងកម្លាំងប្រដាប់អាវុធបានថ្លែងការគាំទ្រ និងអំពាវនាវឲ្យមានការបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។ ចំណែកឯការប្រើប្រាស់យានជំនិះរបស់រដ្ឋ ខុមហ្វ្រែលពុំបានទទួលរបាយការណ៍គ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងការប្រើប្រាស់យានជំនិះដែលមានស្លាកសញ្ញារដ្ឋ ជាពិសេសការប្រើប្រាស់ថវិកា ឬប្រេងសាំងដែលបម្រើឱ្យគណបក្សនយោបាយ ។

## លទ្ធផលសង្ខេបសង្កេតប្រព័ន្ធផ្សព្វផ្សាយ

ការសង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយដែលគិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១១ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១២ បានបង្ហាញថា គណបក្សប្រជាជនកម្ពុជានៅតែទទួលបានការផ្សព្វ-ផ្សាយច្រើនជាងគេ ដែលមានសូរ (Tune) វិជ្ជមានច្រើនចំពោះគណបក្សនេះ ជាពិសេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយរដ្ឋ ខណៈដែលគណបក្សប្រឆាំង ឬមិនកាន់អំណាចផ្សេងទៀតទទួលបានការផ្សព្វផ្សាយតិចតួចដែលមានសូរអវិជ្ជមានច្រើនចំពោះពួកគេ។

***ប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍៣*** គឺ ទូរទស្សន៍ជាតិកម្ពុជា ស៊ីធីអិន និងបាយ័នព័ត៌មាន នៅតែបន្តផ្សព្វផ្សាយលម្អៀងទៅកាន់គណបក្សកាន់អំណាច ទាំងរយៈពេល និងខ្លឹមសារព័ត៌មាន។ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ទាំង៣ គណ-បក្សប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយសរុប ១៣ម៉ោង ៣៦នាទី ក្នុងនោះខ្លឹមសារវិជ្ជមានមាន ១ម៉ោង១០នាទី៣៦វិនាទី និងអវិជ្ជមានត្រឹមតែ៣០វិនាទី ។ ចំណែកគណបក្សសមរង្ស៊ី ក៏ត្រូវបានផ្សព្វផ្សាយច្រើនផងដែ ប៉ុន្តែផ្តោតក្នុងខ្លឹមសារអវិជ្ជមាន។ គណបក្សសមរង្ស៊ី ត្រូវបានផ្សព្វផ្សាយសរុបប្រមាណ ៨ម៉ោង១៥នាទី ក្នុងនោះខ្លឹមសារអវិជ្ជមាន...

តទៅទំព័រ ៧

# ការសង្កេតប្រព័ន្ធផ្សព្វផ្សាយ

...មានតែ ២នាទី និង៥១វិនាទីប៉ុណ្ណោះ។ រីឯគណបក្សសិទ្ធិមនុស្សវិញត្រូវបានផ្សព្វផ្សាយ សរុបតែ ២ម៉ោង ២៧នាទី និង៣៥វិនាទី ដែលក្នុងនោះមាន ៤៤នាទី៥២វិនាទីក្នុងខ្លឹមសារអវិជ្ជមាន ហើយពុំមានខ្លឹមសារវិជ្ជមានទេ។ ចំណែកគណបក្សហ្វ៊ុនស៊ិនប៉ិចត្រូវបានផ្សព្វផ្សាយសរុប៥៤នាទី៣៥វិនាទីក្នុងខ្លឹមសារអព្យាក្រិតទាំងអស់។ គណបក្សនរោត្តមរណឫទ្ធិត្រូវបានផ្សព្វផ្សាយ ១១នាទី ២៣វិនាទី ដែលក្នុងនោះខ្លឹមសារអវិជ្ជមានមាន ៣នាទី។ រីឯគណបក្សដទៃទៀតត្រូវបានផ្សព្វផ្សាយ តិចជាង១នាទី និងក្នុងខ្លឹមសារអព្យាក្រឹត្យទាំងអស់។

ទូរទស្សន៍ស៊ីធីអិន និងទូរទស្សន៍បាយ័នព័ត៌មាននៅតែបន្តផលិត និងចាក់ផ្សាយកម្មវិធីរបស់ខ្លួន ដូចជា សន្ទនាថ្ងៃព្រហស្បតិ៍ និងវេទិកាបញ្ញាជន-ស៊ីធីអិន និងកម្មវិធីបទអត្ថាធិប្បាយព័ត៌មានថ្មី-បាយ័នព័ត៌មាន ជាប្រចាំដែលព័ត៌មាននោះបានរិះន់វាយប្រហារគណបក្សប្រឆាំង តែការពារ និងសរសើរគណបក្សកាន់អំណាច និងរាជរដ្ឋាភិបាល។

*ប្រព័ន្ធផ្សព្វផ្សាយវិទ្យុ) FM 96 MHz និង AM 918 KHz)* បានផ្សាយតិចតួចពីគណបក្សនយោបាយ ដោយក្នុងនោះការផ្សាយពីគណបក្សប្រជាជនកម្ពុជាមាន ៧ម៉ោង ៣៩នាទី ៤៤វិនាទី ដែលក្នុងនោះដែរ ២០នាទី ៣២វិនាទី បានលើកសរសើរពីគណបក្សប្រជាជនកម្ពុជា។ គណបក្សសមរង្ស៊ី មានរយៈពេលសរុប ៨ម៉ោង ៤៥នាទី ហើយក្នុងនោះខ្លឹមសារអវិជ្ជមានមាន ១១នាទី ៩វិនាទី ចំណែកឯខ្លឹមសារវិជ្ជមានមាន ៣នាទី ១២វិនាទី។ រីឯគណបក្សសិទ្ធមនុស្សវិញមានត្រឹមតែ ១២ នាទី និង ៩វិនាទី ក្នុងនោះខ្លឹមសារអវិជ្ជមានមាន ១នាទី ៣៣វិនាទី និងពុំមានខ្លឹមសារវិជ្ជមានទេ។ គណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី មានរយៈពេលច្រើនដោយសារតែ ក្នុងខែមករា មានការឃោសនាបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាដែល គ.ជ.ប បានអនុញ្ញាតឲ្យមានការឃោសនារបស់គណបក្សនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរដ្ឋនេះ។

***វិទ្យុឯករាជ្យក្នុងប្រទេស និងក្រៅប្រទេស (វិទ្យុ FM 105MHz វិទ្យុ FM 106.5MHz វិទ្យុសម្លេង សហរដ្ឋអាមេរិក វិទ្យុអាស៊ីសេរី និងវិទ្យុបារាំងអន្តរជាតិ*** បានផ្សព្វផ្សាយច្រើនពីគណបក្សប្រឆាំង តែបានផ្សព្វផ្សាយតិចតួចពីគណបក្សប្រជាជនកម្ពុជាកាន់អំណាច។ ខ្លឹមសារផ្សព្វផ្សាយនៅក្នុងប្រព័ន្ធវិទ្យុទាំងនេះ សម្រាប់គណបក្សនយោបាយ គឺចម្រុះទាំងវិជ្ជមាន អវិជ្ជមាន និងអព្យា - ក្រឹត។

គណបក្សសមរង្ស៊ី ត្រូវបានផ្សព្វផ្សាយសរុប ៩ម៉ោង ១៣នាទី ៤៨វិនាទី ដែលក្នុងនោះខ្លឹមសារវិជ្ជមានមាន ១នាទី៣៩វិនាទី និងអវិជ្ជមានមាន ១៦នាទី៤១វិនាទី។ ក្នុងម៉ោងសង្កេតនេះ គណបក្សសិទ្ធិមនុស្សត្រូវបានផ្សព្វផ្សាយរយៈពេល ៥ម៉ោង ២៣នាទី



អ្នកស្មគ្រចិត្តខុមប្រ្វែល កំពុងសង្កេតលើប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍បាយ័នឆ្នាំ២០១១

៤៣វិនាទី ក្នុងនោះខ្លឹមសារវិជ្ជមាន៤៣នាទី ៥៧វិនាទី និងអវិជ្ជមាន ៤នាទី ៣៩វិនាទី ដោយមិនគិតពីគណបក្សនេះមានម៉ោងផ្សាយ របស់ខ្លួននៅវិទ្យុ FM105MHz ជាប្រចាំ។ រីឯគណបក្សប្រជាជនកម្ពុជាត្រូវបានបង្ហាញចំនួន ៤ម៉ោង ៤៣នាទី ១៣វិនាទី ដោយក្នុងនោះខ្លឹមសារអវិជ្ជមានមាន ៣០នាទី ៧វិនាទី និងខ្លឹមសារវិជ្ជមានមាន ១នាទី ៦វិនាទី។

ដោយឡែក វិទ្យុសំបុកឃ្មុំ FM105MHz គឺជាវិទ្យុឯកជន និងជាស្ថានីយ៍តែមួយគត់ ដែលផ្តល់ឱកាសអោយគ្រប់តួអង្គនយោបាយរួមមានគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ប្រជាពលរដ្ឋ គ្រប់និន្នាការនយោបាយ និងវិទ្យុអន្តរជាតិផ្សាយជាភាសាខ្មែរចាក់ផ្សាយនៅក្នុងកម្មវិធីវិទ្យុនេះ។ គណបក្សនយោបាយ និងបុគ្គលមួយចំនួន បានទិញម៉ោងវិទ្យុសំបុកឃ្មុំ FM105MHz មានដូចជា គណបក្សសិទ្ធិមនុស្ស គណបក្សសម្ព័ន្ធប្រជាធិបតេយ្យ គណបក្សនរោត្តរណឫទ្ធិ ការផ្សាយសម្លេងសង្គមស៊ីវិល កម្មវិធីរបស់បណ្ឌិត ឈឹម ផលភារុណ កម្មវិធីវិទ្យុអាស៊ីសេរី វិទ្យុសម្លេង-សហរដ្ឋអាមេរិក និងមានកម្មវិធីមតិប្រជាពលរដ្ឋ (សម្រាប់អ្នកទូរស័ព្ទចូល)។ វិទ្យុនេះបានផ្តល់ឱកាសដល់គណបក្សនយោបាយជាពិសេស គណបក្សប្រឆាំងដើម្បីបញ្ចេញទស្សនៈ នយោបាយ កម្មវិធីនយោបាយ និងបញ្ហាសង្គម។ ជាងនេះទៅទៀតវិទ្យុនេះក្លាយ ជាសង្វៀននយោបាយសំខាន់សំរាប់គ្រប់តួអង្គនយោបាយ និងប្រជាពលរដ្ឋ។ វិទ្យុនេះមិនត្រឹមតែជាកន្លែងសម្រាប់គណបក្សប្រឆាំង និងប្រជាពលរដ្ឋគាំទ្រគណបក្សប្រឆាំងរិះគន់រដ្ឋាភិបាល និងគណបក្សកាន់អំណាចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកន្លែងគណបក្សប្រឆាំងនិយាយរិះគន់គ្នាទៅវិញទៅមកផងដែរ។

ខុមប្រ្វែល បានសង្កេតឃើញថា គណបក្សសមរង្ស៊ី គណបក្សសិទ្ធិមនុស្ស និងគណបក្សសម្ព័ន្ធប្រជាធិបតេយ្យបានរិះគន់ទៅលើរដ្ឋាភិបាល និងគណបក្សកាន់អំណាច។ មិនតែប៉ុណ្ណោះ



រូបភាព ៖ ស្រី សុភ័ក្ត្រ

១៤-ឧសភា-២០១២ ៖ លោក **សុក សំអឿន** សមាជិកគណៈកម្មាធិការនាយក ខុមហ្វ្រែល ផ្តល់សម្ភាសន៍ជូន កម្មវិធីសមធម៌ របស់ទូរទស្សន៍ជាតិកម្ពុជា ក្រោយសិក្ខាសាលា

គណបក្សទាំងបី ព្រមទាំងគណបក្សនរោត្តមរណឫទ្ធិបានរិះគន់គ្នាទៅវិញទៅមក។ ក្រៅពីនេះ កម្មវិធីរបស់វិទ្យាស្ថានពលរដ្ឋវិទ្យា ដែលមានលោកបណ្ឌិត **ឈឹម ផលភារុណ** បានធ្វើការរិះគន់ទៅលើគណបក្សប្រឆាំងទាំងអស់។ ជាពិសេសប្រធានវិទ្យុសំបុកឃ្មុំលោក **ម៉ម សូណង់ដូ** មិនត្រឹមតែរិះគន់ទៅលើគណបក្សកាន់អំណាចប៉ុណ្ណោះទេប៉ុន្តែថែមទាំងរិះគន់ទៅលើគណបក្សប្រឆាំងទៀតផង។

សកម្មភាពទាំងអស់នេះបានធ្វើអោយវិទ្យុសំបុកឃ្មុំដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម ព្រោះបានផ្តល់អោយអ្នកស្តាប់ទាំងអស់បានទទួលនូវព័ត៌មានគ្រប់ប្រភេទទាំងវិជ្ជមាន និងអវិជ្ជមានរបស់តួអង្គនយោបាយ ជាពិសេសគណបក្សនយោបាយ និងអ្នកនយោបាយ។

ប៉ុន្តែអ្វីដែលគួរឲ្យបារម្ភវិទ្យុសំបុកឃ្មុំ FM 105 MHz មានកម្មវិធីមតិប្រជាពលរដ្ឋដែលមានប្រធាន បទទាក់ទងទៅនឹងការមិនឲ្យប្រជាពលរដ្ឋទៅបោះឆ្នោត។ កម្មវិធីនេះអាចជះឥទ្ធិពលទៅលើប្រជាពលរដ្ឋ ដែលអាចនឹងមិនទៅបោះឆ្នោតដោយសារតែការគាំទ្រកម្មវិធីនេះ។

យ៉ាងណាមិញ ប្រព័ន្ធផ្សព្វផ្សាយវិទ្យុសំបុកឃ្មុំមិនបានផ្តល់ផលអវិជ្ជមានទាំងស្រុងទេចំពោះគណបក្សកាន់អំណាច តែគ្រប់គណបក្សនយោបាយសុទ្ធតែទទួលបានចំណុចវិជ្ជមាន និងអវិជ្ជមាន។

## ស្ថានភាពទូទៅជុំវិញការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ ឆ្នាំ២០១២

ក្នុងដំណាក់កាលនៃការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទី៣ ឆ្នាំ២០១២ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែមីនា ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២នេះ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា - ខុមហ្វ្រែល បាននឹងកំពុងដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួនប្រមាណ២២០នាក់ ដែលធ្វើការសង្កេតនៅលើឃុំ/សង្កាត់ចំនួន ២០៤ ទូទាំងប្រទេស។

ក្នុងដំណាក់កាលចុះបញ្ជីបេក្ខជនគណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ អាណត្តិ៣ ចាប់ពីថ្ងៃទី០១ ខែមីនា ដល់ថ្ងៃទី១៧ ខែមេសា តួលេខបណ្តោះអាសន្នរបស់ គ.ជ.ប បានឲ្យដឹងថាមានគណបក្សនយោបាយចំនួន ១០ បានដាក់បញ្ជីបេក្ខជនរបស់ខ្លួនសម្រាប់ចូលប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ។ ស្របពេលនេះដែរ មានការរាយការណ៍អំពីភាពមិនប្រក្រតីមួយចំនួនបានកើតឡើងក្នុងដំណាក់កាលដំបូងនេះ ដែលរួមមានដូចជាការគំរាមកំហែង និងការលំបាកនានារបស់គណបក្សមួយចំនួនដែលចូលរួម។ ជាក់ស្តែងបេក្ខជនក្រុមប្រឹក្សាឃុំក្នុងឃុំឆ្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ របស់គណបក្សសមរង្ស៊ី លោក **ស៊ុយ ស៊ីម** ថ្មីៗនេះត្រូវបានសាលាដំបូងខេត្តកំពង់ធំ បានចេញលិខិតជូនដំណឹងក្នុងសំណុំរឿងអនុវត្តដោយបង្ខំបង្គាប់ឲ្យលោកត្រូវរុះរើផ្ទះចេញពីដីរបស់លោកដែលកំពុងកាន់កាប់។ គណបក្សសមរង្ស៊ីហៅករណីថាជាករណីគំរាមកំហែងផ្នែកនយោបាយ។

ជាមួយគ្នានេះផងដែរគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ លើកលែងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច បានលើកឡើងពីភាពមិនប្រក្រតី និងការលំបាកមួយចំនួនដូចជា៖

» យ៉ាងហោចណាស់មានគណបក្សប្រជាធិបតេយ្យបានលើកពីលំបាកក្នុងការបំពេញលក្ខខណ្ឌរបស់ គ.ជ.ប ដូចជាការខ្វះលិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថាពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះបោះឆ្នោត និងឯកសារមួយចំនួនទៀត។

» សមត្ថភាពរបស់មន្ត្រី គឃ/គសប មួយចំនួនមិនទាន់យល់ច្បាស់អំពីនីតិវិធីស្តីពីការចុះបញ្ជីបេក្ខជនគណបក្សនយោបាយ...

តទៅទំព័រ ១៦

# ឃ្លាំមើល សភា និងតំណាងរាស្ត្រ

របាយការណ៍ឆ្នាំទី៣ លេខ១៦/ នីតិកាលទី៤/ ខែតុលា-ធ្នូ

រដ្ឋសភាជាតិក្នុងខែតុលា ដល់ខែធ្នូ ឆ្នាំ២០១១ គឺជារយៈពេលសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៧ ដែលស្ថិតនៅក្នុងរយៈពេលនេះ រដ្ឋសភាបានអនុម័តនូវសេចក្តីព្រាងច្បាប់ សេចក្តីស្នើច្បាប់ និងកិច្ចព្រមព្រៀងផ្សេងៗចំនួន**១១ ឯកសារ** ប៉ុន្តែមានបញ្ហាចំរុងចំរាស់ទៅលើការពិភាក្សាសេចក្តីព្រាងច្បាប់ថវិការជាតិ និងការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ។

បើទោះជាក្នុងពេលនេះរដ្ឋសភាមានការមមាញឹកក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ក្តីក៏អ្នកតំណាងរាស្ត្របានខិតខំចុះមូលដ្ឋានដើម្បីជួបប្រជាពលរដ្ឋ និងជួយអន្តរាគមន៍បញ្ហាផ្សេងទៅអាជ្ញាធរនិងរដ្ឋាភិបាល ។

**រូបសញ្ញាគណបក្សប្រើក្នុងរបាយការណ៍នេះ**

គណបក្ស ប្រជាជនកម្ពុជា

គណបក្ស សមរង្ស៊ី

គណបក្ស សិទ្ធិមនុស្ស

គណបក្ស ហ្វ៊ុនស៊ិនប៉ិច

គណបក្ស នរោត្តមរណឫទ្ធិ

## ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ក្នុងពេលប្រជុំពេញអង្គ

រដ្ឋសភាក្នុងរយៈពេល៣ខែនេះ បានបើកសម័យប្រជុំលើកទី៧ របស់ខ្លួនចំនួន**៩ព្រឹក** បានពិភាក្សា និងអនុម័តលើរបៀបវារៈចំនួន**១៣** ដែលក្នុងនោះមាន **៨**ជាច្បាប់ សេចក្តីព្រាង **៣**ជាការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត និង**២**ទៀតជាព្រះរាជសាររបស់ព្រះមហាក្សត្រ និងរបាយការណ៍ស្តីពីការចុះមូលដ្ឋានរបស់តំណាងរាស្ត្រចន្លោះសម័យប្រជុំលើកទី៦ និងទី៧ មានន័យថា ជាមធ្យមរដ្ឋសភាពិភាក្សា និងអនុម័តក្នុងមួយព្រឹកបានប្រមាណជាង ១របៀបវារៈ។

ក្នុងកំឡុងពេលនេះមានតែអ្នកតំណាងរាស្ត្រចំនួន**២១រូប** មកពីគណបក្សចំនួន៣ ក្នុងចំណោមគណបក្សចំនួន៥ មានអាសនៈនៅរដ្ឋសភាបានឡើងបញ្ចេញមតិមានចំនួន**៥៤៤នាទី** ជាពិសេសទៅលើតួអង្គរាជរដ្ឋាភិបាល ការផ្តល់អនុសាសន៍លើសេចក្តីព្រាងច្បាប់កំពុងពិភាក្សារបៀបវារៈកំពុងពិភាក្សា តួអង្គរដ្ឋសភា និងតួអង្គជាតំណាងរាស្ត្រដទៃ។

ជាមធ្យម អ្នកតំណាងរាស្ត្រ១រូប បញ្ចេញមតិបាន២៦នាទី ព្រោះថាភាគច្រើនប្រធានក្រុមនៃអ្នកតំណាងរាស្ត្របានឡើងបញ្ចេញមតិពិភាក្សាច្រើនជាងគេ។

ចំណែកខ្លឹមសារនៃការបញ្ចេញមតិទៅលើតួអង្គខាងលើ ក្នុងន័យអព្យាក្រឹតមានចំនួន២៨៣នាទី (ស្មើនឹង៥២%នៃការបញ្ចេញមតិសរុប) ខ្លឹមសារវិជ្ជមាន ឬសរសើរដល់តួអង្គខាងលើមានចំនួន១២១នាទី (២២%) និងខ្លឹមសារអវិជ្ជមាន ឬរិះគន់មានចំនួន១៤០ (ស្មើនឹង២៦%)។

អ្នកតំណាងរាស្ត្រមកពីគណបក្សប្រជាជនកម្ពុជាបានគាំទ្ររាល់គ្រប់សេចក្តីព្រាង/ស្នើច្បាប់ដែលរាជរដ្ឋាភិបាលស្នើនោះបានឡើងបញ្ចេញមតិចំនួន១០រូប (ស្ត្រី៣រូប) ចំនួន៣៦ដង ស្មើនឹង២៩៣នាទី ដែលជាមធ្យមអ្នកតំណាងរាស្ត្រគណបក្សនេះ ១រូបបញ្ចេញមតិបាន៣០នាទី។ ការបញ្ចេញមតិភាគច្រើនរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សនេះគឺ លើកសរសើរលើការងាររបស់រាជរដ្ឋាភិបាលដែលបានខិតខំប្រឹងប្រែងដើម្បីធ្វើច្បាប់ រដ្ឋសភា សរសើរចំពោះបុគ្គលនាយករដ្ឋមន្ត្រី ការឆ្លើយតបនឹងតំណាងរាស្ត្រដទៃក្នុងន័យបំភ្លឺ និងលើកអំណះអំណាងជួយការពារសេចក្តីព្រាងច្បាប់ ក៏ដូចជាឆ្លើយឆ្លងជាមួយនឹងអ្នកតំណាងរាស្ត្រដទៃមកពីគណបក្សផ្សេងផងដែរ។

ចំណែកអ្នកតំណាងរាស្ត្រមកពី គណបក្សសមរង្ស៊ីបានឡើងបញ្ចេញមតិចំនួន១០រូប (ស្ត្រី២រូប) បានឡើងបញ្ចេញមតិចំនួន២២ដង ដែលស្មើនឹង២៤៥នាទី។ ជាមធ្យមតំណាងរាស្ត្រ១រូប បញ្ចេញមតិបាន ២៥នាទី។ ការបញ្ចេញមតិរបស់តំណាងរាស្ត្រគណបក្សនេះ បានផ្លាស់ប្តូរពីការនិយាយដែលកន្លងមកធ្លាប់តែរិះគន់ខ្លាំងៗអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ មន្ត្រីរាជការ និងរដ្ឋាភិបាល បែរមកនិយាយភាគច្រើនគឺផ្តោតលើការលើកឡើងលើការរិះគន់ ជជែកពីចំនុចខ្វះខាតរបស់សេចក្តីព្រាងច្បាប់ ផ្តល់អនុសាសន៍ និងលើកជាសំណួរដល់រាជរដ្ឋាភិបាលជាអ្នកការពារសេចក្តីព្រាងច្បាប់ រួមទាំង បញ្ហាប្រឈមផ្សេងៗរបស់មណ្ឌល។ អ្នកតំណាងរាស្ត្រគណបក្សនេះបានពហិការមិនចូលរួមជជែកពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកា ២០១២ និងច្បាប់ផ្សេងក្រោយៗទៀត ព្រោះគណបក្សនេះយល់ថា រដ្ឋសភាមានអធម្មនុញ្ញភាពរួចទៅហើយ ក្រោយពីសមាជិករបស់ខ្លួនបានលាឈប់ចំនួន៣រូប។

អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ១រូបបានបញ្ចេញមតិចំនួន៦នាទី ដែលការបញ្ចេញមតិនេះនិយាយពាក់ព័ន្ធនឹងរដ្ឋសភាអនុសាសន៍លើសេចក្តីព្រាងច្បាប់របៀបវារៈកំពុងពិភាក្សា រដ្ឋសភា និងរាជរដ្ឋាភិបាល។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបន្តឈឺចាប់ដោយគ្មានសម្លេង និងមតិក្នុងរដ្ឋសភា ហើយក៏មិនបានលើកដៃគាំទ្រលើសេចក្តីព្រាងច្បាប់មួយចំនួនដែរ។ ទោះបីយ៉ាងណាក៏គណបក្សនេះនៅតែធ្វើពហិការជារឿយៗចំពោះសេចក្តីព្រាងច្បាប់ណាដែលគណបក្សគិតថា មិនគាំទ្រ ឬសេចក្តីព្រាងច្បាប់នេះនៅមានការខ្វះខាតច្រើនមិនទាន់ដល់ពេលត្រូវអនុម័ត។

## តារាងទី១៖ អ្នកតំណាងរាស្ត្រប្មានបញ្ចេញមតច្រើនជាងគេ៥រូប ក្នុងសម័យប្រជុំលើកទី៧

**អ្នក**តំណាងរាស្ត្រ **ជាម យៀប** មកពីគណបក្សប្រជាជនកម្ពុជាមណ្ឌលព្រៃវែងជាអ្នកតំណាងរាស្ត្របានបញ្ចេញមតិច្រើនជាងគេមានដល់ទៅ១២លើក ស្មើនឹង៩២នាទី ឬ១ម៉ោង៣២នាទី ដែលភាគច្រើនក្នុងការបញ្ចេញមតិនេះ គឺក្នុងន័យអព្យាក្រឹតហើយបើទោះជាការបញ្ចេញមតិក្នុងន័យអវិជ្ជមានមានតែ៦នាទី តែជាចំនួនច្រើនជាងគេបើធៀបនឹងអ្នកតំណាងរាស្ត្រដ៏ទៃបានបញ្ចេញមតិ។

| លរ | ឈ្មោះអ្នកតំណាងរាស្ត្រ | គណបក្ស | ចំនួនដង | អព្យាក្រឹត | វិជ្ជមាន | អវិជ្ជមាន | សរុប |
|---|---|---|---|---|---|---|---|
| ១ | ឯកឧត្តម ជាម យៀប | | ១២ | ៦៧ | ១៩ | ៦ | ៩២ |
| ២ | ឯកឧត្តម ប៉ែន បញ្ញា | | ៩ | ៥០ | ៣៨ | ០ | ៨៨ |
| ៣ | ឯកឧត្តម យឹម សុវណ្ណ | | ៦ | ១៩ | ៦ | ៣៦ | ៦១ |
| ៤ | ឯកឧត្តម សុន ឆ័យ | | ៥ | ៣៥ | ៣ | ១៨ | ៥៦ |
| ៥ | ឯកឧត្តម ឈាង វុន | | ៧ | ៣១ | ១៣ | ៤ | ៤៨ |

អ្នកតំណាងរាស្ត្រ **ប៉ែន បញ្ញា** មណ្ឌលព្រៃវែងនៃគណបក្សប្រជាជនកម្ពុជាបានឈរលេខរៀងទី២ បានបញ្ចេញមតិចំនួន៩លើក ស្មើនឹង៨៨នាទី (ឬ១ម៉ោង ២៨នាទី) បានបញ្ចេញមតិក្នុងន័យ វិជ្ជមានច្រើនជាងគេចំនួន៣៨នាទី។

អ្នកតំណាងរាស្ត្រលេខរៀងទី៣ គឺអ្នកតំណាងរាស្ត្រ **យឹម សុវណ្ណ** មកពីគណបក្សសមរង្ស៊ីមណ្ឌលភ្នំពេញបានបញ្ចេញមតិចំនួន ៦លើក ដែរគឺ ៦១នាទី ស្មើនឹង១ម៉ោង១នាទី ហើយបានបញ្ចេញមតិច្រើនជាងគេលើចំនួនអវិជ្ជមានចំនួន ៣៦នាទី។

អ្នកតំណាងរាស្ត្រ **សុន ឆ័យ** បានឈរនៅលេខរៀងលេខ៤ ក្នុងចំណោមតំណាងរាស្ត្រទាំង៥ ដែលបានបញ្ចេញមតិច្រើនជាងគេបានចំនួន ៥៦នាទី និងតំណាងរាស្ត្រ **ឈាង វុន** បានបញ្ចេញមតិនៅលំដាប់ទី៥ ច្រើនជាងគេក្នុងចំណោមតំណាងរាស្ត្រដែលបានឡើងបញ្ចេញមតិចំនួន ២១រូប។

## ភាពចំរូងចំរាស់លើច្បាប់ថវិកាឆ្នាំ ២០១២

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកាឆ្នាំ២០១២ ត្រូវបានពិភាក្សា និងអនុម័តក្នុងរយៈតែមួយព្រឹក គឺនៅព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា កន្លងទៅនេះដោយគណបក្សប្រឆាំងគិតថាជាថ្ងៃដែលរដ្ឋសភាមានអធម្មនុញ្ញភាព ការពិភាក្សានៅក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភាទៀតសោធក៏មិនមានការជជែកដេញដោលច្រើននោះទេ ហើយរយៈពេលដែលរដ្ឋសភាចាប់ផ្តើមធ្វើការពិនិត្យលើសេចក្តីព្រាងច្បាប់រហូតដល់ពេលប្រជុំពេញអង្គនេះក៏មានរយៈពេលខ្លីផងដែរ។ តែទោះបីជាយ៉ាងណាក៏សេចក្តីព្រាងច្បាប់នេះនៅតែអនុម័តដោយរដ្ឋសភាក្រោមសម្លេងគាំទ្រ ៨៦/៨៦ ដោយគ្មានសម្លេងមកពីគណបក្សប្រឆាំង។

មុនការពិភាក្សាតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីចំនួន៣រូប បានសុំលាឈប់ ពីសមាជិកភាពសភាដែលអាចបង្កើតឲ្យអធម្មនុញ្ញភាព។ ផ្អែកលើមាត្រាទី៧៦នៃរដ្ឋធម្មនុញ្ញ តំរូវឲ្យរដ្ឋសភាមានសមាជិកយ៉ាងតិច ១២០រូប។ គឺដើម្បីការបង្កើតបញ្ហានេះ *"ដើម្បីអោយមានវិបត្តិធម្មនុញ្ញមួយអោយអន្តរជាតិចាប់អារម្មណ៍អ្នកអោយជំនួយចាប់អារម្មណ៍អោយគេពន្យាក្នុងការអោយ ជំនួយដែលសមាជិកគណបក្ស សម រង្ស៊ី ស្មគ្រ័ចិត្តទាំងអស់បង្កើតព្រឹត្តិការណ៍មួយដើម្បីបង្កើតវិបត្តិធម្មនុញ្ញ។"* នេះបើតាមសំដីលើកឡើងរបស់អតីតអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** កាលពីសន្និសីទកាសែតថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១១ នៅទីស្នាក់ការគណបក្ស។ មិនត្រឹមតែប៉ុណ្ណោះ អ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សក៏បានពហិកាមិនចូលរួមប្រជុំ និងប្រកាសមិនគាំទ្រសេចក្តីព្រាងច្បាប់នេះដែរ ដោយសារគណបក្សនេះយល់ថា សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកា២០១២ មានការពន្យល់ថាមាន កំណើនបំណុលពីបរទេសកាន់តែច្រើនដែលទាមទារឲ្យរដ្ឋាភិបាលត្រូវតែកំចាត់អំពើពុករលួយក្នុងក្រសួង ការចំនាយខ្ជះខ្ជាយ សើរើនូវកិច្ចសន្យាសម្បទានដែលបាត់ប្រយោជន៍ជាតិ។

ចំពោះការមិនចូលរួមក្នុងសម័យប្រជុំរដ្ឋសភារបស់គណបក្សទាំងពីរខាងលើនេះត្រូវបានអ្នកតំណាងរាស្ត្រ **ឈាង វុន** មកពីមណ្ឌលបាត់ដំបងរបស់គណបក្សប្រជាជនកម្ពុជាយល់ថា នេះជានយោបាយដែលគណបក្សប្រឆាំងចង់ឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍន៍ជាតិដើម្បីគណបក្សប្រជាជនកម្ពុជាបានកើនសម្លេង *"កុំមានការព្រួយបារម្ភណ៍ដូចអ្នកនយោបាយគេយកមកនិយាយផ្សព្វផ្សាយយកមកនិយាយនោះទេ។ នយោបាយពួកគេធ្វើអោយមានការសង្ស័យ ធ្វើអោយយ៉ាងណាអោយរាំងស្ទះកុំអោយមានស្ពានមានថ្នល់កុំអោយមានសាលារៀនកុំអោយមានភ្លើង"*

សេចក្តីព្រាងច្បាប់ដែលរដ្ឋាភិបាលស្នើថាចាត់ទុកជាការប្រញាប់នេះ បានចំណាយពេលប្រជុំពិភាក្សា និងអនុម័ត អស់រយៈ១ព្រឹក ដែលក្នុងនោះមានអ្នកតំណាងរាស្ត្រចំនួន ៤រូប មកតែពីគណបក្សប្រជាជនកម្ពុជា ឡើងបញ្ចេញមតិចំនួន៨ដង អស់រយៈ៩០នាទី ស្មើនឹង១ម៉ោង ៣០នាទី ចំនួននាទីនៃការបញ្ចេញមតិនេះគឺ តិចជាងការពិភាក្សាហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកា ២០១១ ដែលចំណាយពេលអស់ ២ព្រឹក ...

តទៅទំព័រ ១១

និង១លាច ហើយតំណាងរាស្ត្រមកពី ២គណបក្ស គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសមរង្ស៊ី ចំនួន១២រូប បានឡើងបញ្ចេញមតិយោបល់ចំនួន ១៨ដង ស្មើនឹង ២៤៨នាទី (៤ ម៉ោង ៨នាទី) ។ ការបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ លើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកា ២០១២ ភាគច្រើនផ្តោតលើការសរសើរលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលធ្វើឲ្យមានកំនើនសេដ្ឋកិច្ច បង្ក្រាបបទល្មើសជលផល ប្រើប្រាស់ថវិកាជាតិចំទិសដៅទៅលើក្រសួងកសិកម្ម និងបង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធពេញផ្ទៃប្រទេស។ លើកឧទាហរណ៍ដូចអ្នកតំណាងរាស្ត្រ ឈាង វុន តំណាងរាស្ត្រ បានលើកឡើងក្នុងថ្ងៃប្រជុំពេញអង្គថា *"ខ្ញុំយល់ឃើញថា ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង២០១២នេះ គឺជាគំរោងច្បាប់ដែលមានឆន្ទៈក្នុងការលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋ ដូចលើកកំពស់ប្រទេសជាតិ ច្បាប់នេះមានសារៈសំខាន់ណាស់សំរាប់វិស័យការពារ សន្តិសុខសង្គម។"*

បើទោះបីជាយ៉ាងណា ក៏មានការលើកឡើងពីខាងតំណាងរាស្ត្រគណបក្សប្រឆាំង និងគណបក្សមានសម្លេងតិចថា សេចក្តីព្រាងច្បាប់ល្អអាចទទួលយកបានលុះត្រាតែមានសម្លេងការអនុម័តមកពីគ្រប់គណបក្សចូលរួមពិភាក្សា និងអនុម័ត។ ក្នុងការអនុម័ត និងការពិភាក្សា គ្មានតំណាងគណបក្សប្រឆាំងចូលរួមផងនោះ នឹងធ្វើអោយសភាជាតិដែលជាស្ថាប័ននិតីប្បញ្ញត្តិគ្មានប្រជាធិបតេយ្យនៅទេ។ អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មណ្ឌលកំពត របស់គណបក្សសមរង្ស៊ីបានមានប្រសាសន៍ថា រដ្ឋសភាមិនមានលក្ខណៈប្រជាធិបតេយ្យទេ រដ្ឋសភាគ្មានសម្លេងពីគណបក្សប្រឆាំង ឬការជជែកបញ្ចេញយោបល់ពីគណបក្សប្រឆាំង។ *"នៅពេលណាគ្មានតំណាងរាស្ត្រមកពីគណបក្សប្រឆាំងនឹង គឺអនុម័តដោយគ្មានការជជែកមួយមាត់សោះ គេមិនដែលសភាណាប្រជាធិយតេយ្យណា ដាក់ច្បាប់ឲ្យអនុម័ត អនុម័តដោយគ្មានការជជែក ដឹងពីលើកដៃយកៗ បង្ហាញឃើញថាសភាកម្ពុជាមិនមែនជាសភាប្រជាធិបតេយ្យទេ។"* ស្របគ្នានេះដែរអ្នកតំណាងរាស្ត្រ **យ៉ែម បុញ្ញឫទ្ធិ** មណ្ឌលព្រៃវែង មកពីគណបក្សសិទ្ធិមនុស្សក៏មានគំនិតយល់ស្របទៅនឹងអ្នកតំណាងរាស្ត្រ មូរ សុខហួរ ដែលថា វាជាការប៉ះពាល់ធ្ងន់ធ្ងរសំរាប់រដ្ឋសភា ប្រសិនបើមិនមានសម្លេងភាគតិចចូលរួមអនុម័តច្បាប់នានា *"យើងយល់ឃើញថាមានការប៉ះពាល់ធ្ងន់ណាស់ ព្រោះរដ្ឋសភាជាស្ថាប័ននិតីប្បញ្ញត្តិជាស្ថាប័នកំពូលរបស់ជាតិ ហើយនៅពេលប្រជុំពេញអង្គរបស់រដ្ឋសភាគួរណាស់មានសម្លេងភាគតិចចូលរួម ជាពិសេសសម្លេងគណបក្សប្រឆាំងនៅពេលដែលគណបក្សសម្លេងភាគតិចក្រៅរដ្ឋាភិបាលទាំង២គណបក្សមិនចូលរួម គឺជាការប៉ះពាល់មួយ គួរតែស្ថាប័ននីតិប្បញ្ញត្តិគិតគូរឡើងវិញមុននឹងសម្រេចកិច្ចការអីមួយ"*។

ដោយឡែកសំរាប់តំណាងរាស្ត្រគណបក្សកាន់អំណាចវិញយល់ថាការអនុម័តច្បាប់នឹងប្រព្រឹត្តទៅធម្មតាបើទោះជាគ្មានសម្លេង ឬការចូលរួមពិភាក្សាពីគណបក្សប្រឆាំងក៏ដោយ ព្រោះនេះជាសិទ្ធិរបស់គេ ប៉ុន្តែអ្វីដែលជាបញ្ហានោះគឺអ្នកតំណាងរាស្ត្រណាដែលអវត្តមានក្នុងពេលប្រជុំដោយមិនមានការអនុញ្ញាតពីប្រធានរដ្ឋសភា នោះពួកគេនឹងត្រូវប្រឈមនឹងការកាត់ប្រាក់ខែ។ **ជាម យៀប** មណ្ឌលព្រៃវែងមកពីគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា *"គឺវាមិនអាចទេ (មិនអាចថាមិនប្រកាសជាសាធារណៈទេ) ហើយវាគ្មានអ្វីប៉ះពាល់ទេ គេគិតតែចំនួនទេ(កូរ៉ុម) តែគាត់ត្រូវតែសុំ ច្បាប់។ អវត្តមានការឈប់តាមតែអំពើចិត្ត ឥឡូវគេកាត់ប្រាក់ខែ ហើយអ្នកដែលមិនបានចូលត្រូវបានអគ្គលេខាដ្ឋានរដ្ឋសភាសុំទៅគណៈកម្មការ អចិន្ត្រៃយ៍ដើម្បីកាត់ប្រាក់ខែ ឥឡូវហ្នឹងសម្តេចប្រធាន និងគណៈកម្មការអចិន្ត្រៃយ៍បានឯកភាពអោយធ្វើ បើមិនអញ្ចឹងទេចេះតែឈប់ពាសវាលពាសកាលមិនចូលរួមប្រជុំ"* ។

ជាមួយគ្នានេះដែរសេចក្តីព្រាងច្បាប់នេះចូលរដ្ឋសភាតែ១លើក ដោយមិនមានការកែប្រែត្រលប់ទៅទីស្តីការគណៈរដ្ឋមន្ត្រីវិញ គឺចូលតាំងពីថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១១ គិតមកដល់ថ្ងៃប្រជុំគឺមានរយៈពេលតែ ២០ថ្ងៃ (ថ្ងៃធ្វើការ )។ រយៈពេលនេះគឺសំរាប់គណៈកម្មការជំនាញរដ្ឋសភាដើម្បីធ្វើការពិនិត្យ មុននឹងដាក់ជូនរដ្ឋសភាពេញអង្គអនុម័ត ប៉ុន្តែជារយៈពេលខ្លីចំពោះសេចក្តីព្រាងច្បាប់សំខាន់បែបនេះ ពាក់ព័ន្ធនឹងថវិកាជាតិ ។

សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកាឆ្នាំ២០១២ មាន ៥ជំពូក និង១៣ មាត្រា គឺដើម្បីអនុម័តឲ្យរដ្ឋាភិបាលនូវទឹកប្រាក់ ១០ ៧៦៧ ៩៨២លានរៀល ប្រមាណនឹង ២៦០០លានដុល្លាអាមេរិច ដើម្បីបែងចែងតាមក្រសួង ស្ថាប័ននានាក្នុងការបំពេញតួនាទីអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ។

»»»ទិន្នន័យការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រត្រូវបានប្រមូលមកពី៖ ការិយាល័យតំណាងរាស្ត្រនៅតាមមណ្ឌលនីមួយៗ សាខាគណបក្សជាប់ឆ្នោតនីមួយៗនៅតាមខេត្ត គេហទំព័រ (website) របស់គណបក្ស ប្រព័ន្ធផ្សព្វផ្សាយ និងរបាយការណ៍របស់អ្នកតំណាងរាស្ត្រ។

»»»អ្នកតំណាងរាស្ត្រអាចផ្តល់ព័ត៌មានពីការចុះមូលដ្ឋានរបស់ខ្លួនតាមអាស័យដ្ឋានដូចខាងក្រោម៖ **គណៈកម្មាធិការ ខុមហ្វ្រែល**

**ផ្ទះ**លេខ១៣៩ ផ្លូវ.១២១ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ ៖ ០២៣ ៨៨៤ ១៥០ / ទូរសារ ៖ ០២៣ ៨៨៥ ៧៤៥
អ៊ីម៉ែល ៖ comfrel@online.com.kh / គេហទំព័រ ៖ www.comfrel.org



## សេចក្តីជូនដំណឹង

# ការជ្រើសរើសអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងឯករាជ្យ

ដើម្បីឲ្យមានការចូលរួមកាន់តែច្រើនក្នុង**ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣** ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២**នាពេលខាងមុខ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ហៅកាត់ថា **ខុមហ្វ្រែល** សូមអំពាវនាវដល់អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការអន្តរជាតិ សមាគម សហជីព និងអ្នកស្ម័គ្រចិត្តឯករាជ្យនានា ចូលរួមដំណើរការបោះឆ្នោត ជាពិសេសអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងនាមជាអ្នកសង្កេតការណ៍ស្ម័គ្រចិត្ត និងឯករាជ្យ ។

ជាអង្គការដែលមានបទពិសោធន៍គួរជាទីមោទនៈ ក្នុងការសម្របសម្រួលអ្នកសង្កេតការណ៍ស្ម័គ្រចិត្តជាង១០០០ នាក់ មកពីអង្គការជាតិ អង្គការអន្តរជាតិ សមាគម និងបណ្តាអង្គការដែលមានមូលដ្ឋានតាមសហគមន៍នៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៤ កន្លងទៅ ខុមហ្វ្រែល មានភាពជឿជាក់ និងប្តេជ្ញាសម្រេច ឱ្យបាននូវបេសកម្មដ៏សំខាន់មួយទៀត ក្នុងការពង្រឹងដំណើរការប្រជាធិបតេយ្យតាមរយៈការសង្កេតការបោះឆ្នោតរួមគ្នាជាថ្មីម្តងទៀត ជាមួយអង្គការ សមាគម បុគ្គលឯករាជ្យ... ដែលមានចំណាប់អារម្មណ៍លើការសង្កេតការណ៍បោះឆ្នោត នៅឆ្នាំ ២០១២នេះ។

ដើម្បីសម្រេចគោលបំណងនេះ ខុមហ្វ្រែល នឹងផ្តល់ជូនកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលលើបេសកកម្មសង្កេតការណ៍បោះឆ្នោតដោយស្ម័គ្រចិត្តនេះ សម្រាប់អង្គការ សមាគម អ្នកស្ម័គ្រចិត្តឯករាជ្យ តាមរយៈកិច្ចជួយស្នើសុំកាតសង្កេតការណ៍បោះឆ្នោតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជួយរៀបចំវគ្គបណ្តុះបណ្តាលជំនាញ ស្តីពីការសង្កេតការណ៍បោះឆ្នោត ការធ្វើ និងបញ្ជូនរបាយការណ៍ និងសៀវភៅណែនាំអ្នកសង្កេតការណ៍បោះឆ្នោត។

ក្នុងន័យនេះ ខុមហ្វ្រែលសូមគោរពអញ្ជើញប្រធាន ឬតំណាងអង្គការជាតិ អន្តរជាតិ អង្គការមានមូលដ្ឋានតាមសហគមន៍ សមាគម សិស្សនិស្សិត និងភាគីពាក់ព័ន្ធដែលមានបំណងចង់ចូលរួមសង្កេតការណ៍បោះឆ្នោតខាងមុខ សូមអញ្ជើញចុះឈ្មោះ និងផ្ញើបញ្ជីឈ្មោះបុគ្គលិក/សហជីវិកដែលមានចំណាប់អារម្មណ៍ មកកាន់ទីស្នាក់ការកណ្តាលខុមហ្វ្រែល ឲ្យបានមុន**ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២** តាមរយៈ៖

»»លោក **ស្រី សុភ័ក្រ** ទូរស័ព្ទ៖ 012 998 364 ឬ អ៊ីម៉ែល៖ sreysopheak@comfrel.org ចំពោះអង្គការ សមាគមន៍ដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ

»»អ្នកស្រី **សន សុម៉ារី** ទូរស័ព្ទ៖ 092 973 174 ឬ អ៊ីម៉ែល៖ somary@comfrel.org និង លោក **មាស សេរីសោភ័ណ** ទូរស័ព្ទ៖ 016 866 898 ឬ អ៊ីម៉ែល៖ sereysophorn@comfrel.org ចំពោះអង្គការ សមាគម ដែលមានទីស្នាក់ការនៅតាមបណ្តាខេត្ត

»»លោក **អ៊ុន សំណាង** ទូរស័ព្ទ ៖ 089 899 897 ឬ អ៊ីម៉ែល៖ samnang@comfrel.org ចំពោះលោក លោកស្រី នាងកញ្ញា ជានិស្សិត

»» លោក **អ៊ូ ឬទ្ធី** ទូរស័ព្ទ ៖ 017 340 722 ឬ អ៊ីម៉ែល៖ ouritthy@comfrel.org និង លោក Bruno SMITH ទូរស័ព្ទ ៖ 088 807 1140 ឬអ៊ីម៉ែល៖ brunosmithv@hotmail.com ចំពោះលោក លោកស្រី នាងកញ្ញា ជាជនបរទេស (E-STO)

### *សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង*

»»លោក **ប្លង់ បឿត** មន្ត្រីបណ្តាញខុមហ្វ្រែល តាមរយៈលេខទូរស័ព្ទ ៖ ០១២ ៤៧១ ៣២៦ ឬ តាមអ៊ីម៉ែល៖ boeurth@comfrel.org ឬ comfrel@online.com.kh

សមាមាត្រនៅគ្រប់កម្រិតផ្សេងទៀតនៃរដ្ឋបាលបោះឆ្នោត។ អនុសាសន៍ ត្រូវបានសម្របសម្រួលដោយ ខុមហ្វ្រែល តាមទស្សនៈរបស់គណបក្សនយោបាយផ្សេងពី គណបក្សប្រជាជន កម្ពុជា កំណែទម្រង់នេះ នឹងបង្កើនជំនឿទុកចិត្ត និងតម្លាភាពនៃរដ្ឋបាលបោះឆ្នោតសម្រាប់ការបោះឆ្នោតដែលនឹងមកដល់។ ខុមហ្វ្រែល នឹងភាគីពាក់ព័ន្ធដទៃទៀត បានដាក់សម្ពាធដើម្បីពិភាក្សាកំណែទម្រង់នេះ។ ប៉ុន្តែមកទល់នឹងពេលនេះ សំណើកំណែទម្រង់ទាំងនេះ មិនទាន់ត្រូវបានពិចារណានៅឡើយទេ។ ខុមហ្វ្រែល ជឿជាក់ថា ទោះបីជាកំណែទម្រង់នេះនៅតែបន្តលើកឡើងនូវចម្ងល់ជាច្រើនអំពីឥទ្ធិពលនៃគណបក្សនយោបាយជាច្រើននៅក្នុងគណៈកម្មាធិការបោះឆ្នោត ចាប់ពីពេលដែលច្បាប់បោះឆ្នោត បានចែងថា គ.ជ.ប អាចធ្វើការពិចារណាត្រឹមតែមតិភាគច្រើនធម្មតា និងតម្រូវការឱ្យមានសមាជិកយ៉ាងតិច ៣រូប ផ្តួចផ្តើម ដែលមានន័យថា គណបក្សនយោបាយផ្សេងពីគណបក្សប្រជាជនកម្ពុជា នឹងមិនមានសមាជិកគ្រប់គ្រាន់ដើម្បីដាក់ឥទ្ធិពលលើដំណើរការសម្រេចចិត្តរបស់ គ.ជ.ប ពីព្រោះពួកគេខ្វះមតិភាគច្រើននៅក្នុងគណៈកម្មាធិការ។ កំណែទម្រង់នេះ ជាក់ស្តែងណាស់នឹងបង្កើនតម្លាភាពនៃដំណើរការបោះឆ្នោត ហើយក៏អនុញ្ញាតឱ្យគណបក្សនយោបាយផ្សេងពីគណបក្សប្រជាជនកម្ពុជា ដើម្បីផ្តួចផ្តើមសំណើកំណែទម្រង់ក្នុងគណៈកម្មាធិការបោះឆ្នោតគ្រប់កម្រិតទាំងអស់។

ទាក់ទងនឹងចំនួនអាសនៈរដ្ឋសភាបច្ចុប្បន្ន ខុមហ្វ្រែល និងភាគីពាក់ព័ន្ធដទៃទៀត រាប់បញ្ចូល ក្រុមអ្នកសង្កេតការណ៍បោះឆ្នោតសហភាពអឺរ៉ុបនៅកម្ពុជា ឆ្នាំ ២០០៨ បានផ្តល់អនុសាសន៍ ដើម្បីបង្កើនចំនួនអាសនៈសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភានៅពេលបន្ទាប់។ តាម ខុមហ្វ្រែល និងក្រុមអ្នកសង្កេតការណ៍បោះឆ្នោតសហភាពអឺរ៉ុបនៅកម្ពុជា ចំនួននៃអ្នកសិទ្ធិបោះឆ្នោតនៅក្នុង៤ មណ្ឌល ក្នុងចំណោម ២៤ មណ្ឌល មានមណ្ឌលខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តសីហនុ និងមណ្ឌលខេត្តកណ្តាល មានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលតម្រូវឱ្យបន្ថែមអាសនៈដើម្បីអនុលោមតាមគោលការណ៍អន្តរជាតិ ស្តីពី សិទ្ធិបោះឆ្នោតជាសកល និងស្មើភាព ដែលបានចែងនៅក្នុង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្នុងមាត្រា ២១។ ក្រុមអ្នកសង្កេតការណ៍បោះឆ្នោតសហភាពអឺរ៉ុបនៅកម្ពុជា បានសន្និដ្ឋាននៅក្នុងរបាយការណ៍ឆ្នាំ២០០៨ របស់ខ្លួនថា តាមស្ថិតិដែលបានផ្តល់ដោយវិទ្យាស្ថានជាតិស្ថិតិ ចំនួននៃពលរដ្ឋក្នុងខេត្ត នឹងតម្រូវឱ្យមានការកែប្រែ ខណៈមានការប្រែប្រួលជាដុំកំភួនក្នុងមណ្ឌលនូវចំនួនប្រជាពលរដ្ឋក្នុងមួយអាសនៈ។ ក្នុងករណីខ្លះ ការប្រែប្រួលមិនបានអនុលោមតាមគោលការណ៍សិទ្ធិអ្នកបោះឆ្នោតជាសកល និងស្មើភាព ដែលបានចែងក្នុង សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២១។ ទោះបីជាយ៉ាងណា ក្នុងខែវិច្ឆិកា គណៈរដ្ឋមន្ត្រីបានសម្រេចរក្សាទុកចំនួនអាសនៈបច្ចុប្បន្ន។ រាជរដ្ឋាភិបាលកម្ពុជា ការពារសេចក្តីសម្រេចដោយយកមូលហេតុកម្រិតហិរញ្ញវត្ថុ ដែលបណ្តាលមកពី វិបត្តិហិរញ្ញវត្ថុពិភពលោក និងវិបត្តិស្បៀងអាហារក្នុងឆ្នាំ ២០១១។ ទោះបីជាយ៉ាងនេះ ខុមហ្វ្រែល ប៉ាន់ប្រមាណថា តម្លៃសម្រាប់ ១២៧ អាសនៈ នឹងកើនឡើងត្រឹម ០.១២% នៃការចំណាយចរន្តសរុបនៃថវិកាជាតិឆ្នាំ ២០១១ ដើម្បីបន្ថែមអាសនៈ។

បញ្ហាដ៏ធំផ្សេងទៀតនៃប្រព័ន្ធច្បាប់បោះឆ្នោតនាពេលបច្ចុប្បន្នដែលអាចដឹងបាន ក្នុងចំណោមភាគីពាក់ព័ន្ធក្នុងស្រុក និងអន្តរជាតិ គឺក្របខណ្ឌច្បាប់បោះឆ្នោតបច្ចុប្បន្ន។ ច្បាប់ ត្រូវបានយល់ឃើញថាមានភាពស្មុគស្មាញពេក ខ្វះខាតនីតិវិធីបណ្តឹងច្បាស់លាស់ និងយន្តការអនុវត្តឱ្យបានសមរម្យ។ ទោះបីជាយ៉ាងណា មិនទាន់មានកំណែទម្រង់ណាមួយ ដែលបានផ្តួចផ្តើម ឬប្រកាសជូនដំណឹងដោយ គ.ជ.ប ដើម្បីធ្វើឱ្យមានក្របខណ្ឌច្បាប់បោះឆ្នោតដ៏ងាយស្រួល។ នាពេលថ្មីៗនេះ មានបណ្តឹង ៨ ផ្សេងៗគ្នាដែលដាក់ទៅ គ.ជ.ប។ លើសពីនេះទៀត ស្ថាប័នផ្សេងៗជាច្រើន បានចែករំលែកនូវការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់បោះឆ្នោត រាប់បញ្ចូល គ.ជ.ប ក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការ។ ខុមហ្វ្រែល បានផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍បោះឆ្នោតឆ្នាំ ២០០៨ ពីការកំណែទម្រង់មួយចំនួនទាក់ទងនឹងក្របខណ្ឌច្បាប់ ដើម្បីបង្កើនភាពជឿទុកចិត្តនៅក្នុងកិច្ចការងាររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ដូចគ្នា នេះដែរ EUEOM Cambodia បានថ្លែងនៅក្នុងរបាយការណ៍ការបោះឆ្នោតរបស់ខ្លួនថា "ជាទូទៅ ក្របខណ្ឌច្បាប់ នៅតែជាសម្រង់អត្ថបទ ហើយមានកម្រិតខុសគ្នាតាមបទដ្ឋានជាច្រើនប្រភេទ និងធម្មជាតិ (រាប់បញ្ចូល បទប្បញ្ញត្តិ សារាចរណ៍ណែនាំ សេចក្តីណែនាំ សៀវភៅណែនាំ, សេចក្តីសម្រេច និងការអប់រំដែលបង្កើតឡើងដោយ គណៈកម្មាការជាតិរៀបចំការបោះឆ្នោត និងក្រសួងពាក់ព័ន្ធជាច្រើន) ដោយពេលខ្លះបានធ្វើឱ្យមានការភ័ន្តច្រឡំលើច្បាប់ដែលគួរផ្សព្វ ផ្សាយ។ ច្បាប់មិនបានដាក់បទដ្ឋានឲ្យច្បាស់លាស់តាម ឋានានុក្រមរបស់វាទេ។ ភាពខ្វះខាតនៃការចូលរួមបង្កើតក្របខណ្ឌច្បាប់ ជាការលំបាកមួយសម្រាប់ភាគីពាក់ព័ន្ធ ដើម្បីទទួលបានវិធានទាំងឡាយ និងត្រូវធ្វើឱ្យពួកគេយល់ឲ្យបានច្បាស់អំពីវិធានទាំងនោះ។

# សិទ្ធិបោះឆ្នោត ៖ ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត

កាលពីអតីតកាល ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតផ្សេងគ្នា បានលើកនូវកង្វល់ជាច្រើនទាក់ទងនឹងភាពមិនប្រក្រតី និងភាពលំបាកនៃបច្ចេកក្នុងការចុះឈ្មោះបោះឆ្នោត។ មានការអះអាងជាច្រើនបានលើកឡើងថា ការចុះឈ្មោះបោះឆ្នោតមិនបានធានាសិទ្ធិបោះឆ្នោតសម្រាប់ពលរដ្ឋទាំងអស់ ហើយអាចមានភាពលម្អៀងទៅរកគណបក្សប្រជាជនកម្ពុជា។ ប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ ត្រូវបានគេរកឃើញដោយភាគីពាក់ព័ន្ធជាច្រើនរាប់បញ្ចូលទាំង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ផងដែរ ថាជាឧបសគ្គមួយដែលធ្វើឱ្យមានបញ្ហាទាំងអស់នោះកើតមានឡើង។ ដូច្នេះអនុសាសន៍មួយចំនួនលើការប្រតិបត្តិការណ៍ចុះឈ្មោះអ្នកបោះឆ្នោត គួរតែធ្វើឱ្យងាយស្រួលដោយដាក់កាតព្វកិច្ចក្នុងការប្រើប្រាស់នូវអត្តសញ្ញាណប័ណ្ណជាតិ។ នៅក្នុងឆ្នាំ២០១១ មានអ្នកបោះឆ្នោតចំនួន៩២% បានប្រើអត្តសញ្ញាណប័ណ្ណរបស់ពួកគេដើម្បីចុះឈ្មោះបោះឆ្នោត។ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែមានអត្តសញ្ញាណប័ណ្ណទេ។ ជាងនេះទៅទៀត រហូតមកដល់ខែមិថុនាឆ្នាំ២០១១ ក៏មិនទាន់ច្បាស់នៅឡើយថាតើមានអត្តសញ្ញាណប័ណ្ណចំនួនប៉ុន្មានដែលនឹងត្រូវផុតសុពលភាព មុនពេលការបោះឆ្នោតមកដល់ ហើយអាចប្រើប្រាស់សម្រាប់ការបោះឆ្នោតលើកក្រោយ។ បញ្ហានេះបានលេចឡើងនូវការសង្ស័យជាច្រើនដែលថា ជាចេតនា ឬអចេតនាលើទម្រង់ចុះឈ្មោះបោះឆ្នោតក្លែងក្លាយនៅតែអាចកើតមាន។ ជំទាស់ទៅនឹងសាវតានេះ ខុមហ្វ្រែល បានយកចិត្តទុកដាក់ផងដែរលើប្រតិបត្តិការណ៍ចុះឈ្មោះប្រចាំឆ្នាំ២០១១នេះ។ ខុមហ្វ្រែល បានដាក់ពង្រាយអ្នកអង្កេតការណ៍ចំនួន ៤៧នាក់ ដើម្បីអង្កេតលើការចុះឈ្មោះបោះឆ្នោត និងអ្នកសង្កេតចំនួន ២៣១ នាក់ ដើម្បីសម្ភាសន៍អ្នកបោះឆ្នោត និងធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត។



០៧-ធ្នូ-២០១១ ៖ អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ ខុមហ្វ្រែល លោក គឹម ឈន ចូលរួមកិច្ចពិគ្រោះយោបល់ ស្តីពីការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១១

ខុមហ្វ្រែល បានរកឃើញថា នៅក្នុងឆ្នាំ២០១១ ភាពវិជ្ជមាន គឺមានកិច្ចខិតខំប្រឹងប្រែងជាច្រើនដែលទទួលយកដោយ រាជរដ្ឋាភិបាលកម្ពុជា និងគ.ជ.ប ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះឈ្មោះបោះឆ្នោតដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ជាដំបូង រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការដោះស្រាយបញ្ហាទៅលើអត្ត-សញ្ញាណប័ណ្ណដែលផុតសុពលភាព ក្នុងឆ្នាំ២០១១ ដោយការអនុម័តអនុក្រឹត្យមួយកាលពីថ្ងៃទី២៣ ខែមិថុនា ដែលបន្តសុពលភាពនៃអត្តសញ្ញាណប័ណ្ណប្រហែលជាង ៤លាន អាចប្រើប្រាស់រហូតដល់ចុងឆ្នាំ ២០១៣។ អនុក្រឹត្យនេះអនុញ្ញាតឱ្យអ្នកបោះឆ្នោតស្របច្បាប់ ប្រើប្រាស់អត្តសញ្ញាណប័ណ្ណទាំងនោះសម្រាប់ការបោះឆ្នោតដែលនឹងមកដល់នៅពេលខាងមុខបាន។ លើសពីនេះទៀត មានវិសោធនកម្មច្បាប់បោះឆ្នោត និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា និងគ.ជ.ប បានធ្វើឱ្យប្រសើរនូវការចុះឈ្មោះអ្នកបោះឆ្នោតប្រចាំឆ្នាំ។ នេះរាប់បញ្ចូលថា គ.ជ.ប និងក្រសួងមហាផ្ទៃ បានសម្រេចដើម្បីជំនួសលិខិតបញ្ជាក់អត្តសញ្ញាណអ្នកបោះឆ្នោតដ៏ចម្រូងចម្រាស់ "ទំរង់ ១០១៨" ដោយទម្រង់ថ្មីមួយ ដែលមានឈ្មោះថា "លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់មប្រើឱ្យការបោះឆ្នោត"។ លិខិតបញ្ជាក់អត្តសញ្ញាណក្រោយនេះ នឹងលំបាកដើម្បីសម្រួលជាងទម្រង់ចាស់ដូចជាតំរូវឲ្យយករូបថតពីរ (២) សន្លឹកជាចាំបាច់ទៅជាមួយក្នុងការស្នើសុំលិខិតនេះ។ យោងតាម គ.ជ.ប លិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់មប្រើឱ្យការបោះឆ្នោតចំនួន ៤២៦,១១៦ សន្លឹក ត្រូវបានចេញឱ្យប្រើប្រាស់សម្រាប់អ្នកបោះឆ្នោតក្នុងឆ្នាំ២០១១។ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងគ.ជ.ប នៅពេលនេះអាចត្រូវបានត្រួតពិនិត្យចំពោះនីតិវិធីនៃការចេញទម្រង់នេះដោយអ្នកសង្កេតការណ៍បោះឆ្នោតខុមហ្វ្រែលផងដែរ។ ករណីនេះមិនដូចជា ករណីដែលបានកើតឡើងកាលពីឆ្នាំ២០០៨ នោះទេ នៅពេលដែល គ.ជ.ប និងក្រុមប្រឹក្សាឃុំ-សង្កាត់ មិនបានផ្តល់នូវចំនួនតួលេខសរុបនៃទម្រង់ ១០១៨ ដែលបានចេញ ខណៈដែល ខុមហ្វ្រែល បានរកឃើញប្រហែលជា ៤៥០,០០០ នៃទម្រង់ទាំងអស់។ ជាវិជ្ជមានដែរ អនុសាសន៍របស់ ខុមហ្វ្រែល ពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃការបោះឆ្នោតដែលទើបបានបង្កើតថ្មី ឬកំណត់ព្រំដែននៃឃុំ-សង្កាត់ ដែលបានទទួលយកដោយ គ.ជ.ប។ វាត្រូវបានយល់ស្របថា ក្រុមប្រឹក្សាឃុំ-សង្កាត់ចាស់..

តទៅទំព័រ ១៥

នៅតែទទួលខុសត្រូវសម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតបឋម ដោយគិតថាអ្នកដែលបានស្នើទៅរស់នៅក្នុងឃុំ-សង្កាត់ថ្មី មិនត្រូវចុះឈ្មោះសម្រាប់ការបោះឆ្នោតម្តងទៀត។

បន្ថែមពីនេះទៀត វិសោធនកម្មច្បាប់បោះឆ្នោត ត្រូវបានអនុម័តដោយរដ្ឋសភាកាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ ដើម្បីធានាថា អ្នកបោះឆ្នោតថ្មីដែលទើបតែមានសិទ្ធិបោះឆ្នោត មានពេលច្រើនថែមទៀតដើម្បីចុះឈ្មោះសម្រាប់ការបោះឆ្នោតដែលនឹងមកដល់ក្នុងឆ្នាំ២០១២ និង២០១៣។ អំឡុងពេលនៃការចុះឈ្មោះអ្នកបោះឆ្នោតទាំងស្រុង រាប់បញ្ចូលទាំងបច្ចុប្បន្នកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោត មានការបន្ថែមពី ៩០ថ្ងៃ ទៅដល់ ១២០ថ្ងៃ ជាថេរវេលានៃការចុះឈ្មោះផ្លូវការដែលបានបន្ថែមពី ២០ថ្ងៃ ទៅ ៤៥ថ្ងៃ និងអំឡុងនៃបណ្តឹងបានបន្ថែមពី ៥ថ្ងៃ ទៅ ១០ថ្ងៃ។ ដូចគ្នាដែរ ចំនួននៃអ្នកមានសិទ្ធិបោះឆ្នោតបានកើតឡើងត្រឹម ៦៦០,២១០ នាក់ ចន្លោះឆ្នាំ២០០៨ ដល់ឆ្នាំ២០១១។ ក្នុងឆ្នាំ២០០៨ អ្នកមានសិទ្ធិបោះឆ្នោតចំនួន ៨,៥៤៣,២៨៣ នាក់ ត្រូវចុះឈ្មោះបោះឆ្នោត ឯអ្នកចុះឈ្មោះក្នុងឆ្នាំ២០១១ មានចំនួន ៩,២០៣,៤៩៣ ដែលនៅក្នុង នោះមានស្ត្រីចំនួន ៤,៨៦១,៨៥៣ និង ៣.៤ លាននាក់គឺជាយុវជនដែលមានអាយុចន្លោះពី ១៨ឆ្នាំ ទៅ ៣០ឆ្នាំ។ តួលេខនេះបានបង្ហាញជាទូទៅថា ការចុះឈ្មោះអ្នកបោះឆ្នោតបានប្រតិបត្តិដោយទទួលជោគជ័យនៅពេលនេះ។ ទោះបីជាយ៉ាងណា មានការព្រួយបារម្ភមួយចំនួនទៀតដែលទាក់ទងទៅនឹងចំនួនតួលេខពិតប្រាកដនៃអ្នកមានសិទ្ធិបោះឆ្នោត និងគុណភាពនៃបញ្ជីឈ្មោះអ្នកបោះឆ្នោតនាពេលបច្ចុប្បន្នសម្រាប់ការបោះឆ្នោតពេលក្រោយ។ តួលេខរបស់ គ.ជ.ប អាចអះអាងថា បានចុះឈ្មោះបោះឆ្នោត ១០៤% នៃអ្នកបោះឆ្នោត ខណៈដែល ខុមហ្វ្រែល បានរកឃើញថា មានត្រឹមតែ ៩៤% នៃអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ដែលបានចុះបញ្ជីពិតប្រាកដ។ សវនកម្មបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់ ខុមហ្វ្រែល ក្នុងឆ្នាំ២០១១ បានរកឃើញថា ១៧.២% នៃអ្នកបោះឆ្នោតដែលបានចុះបញ្ជី មិនមានទិន្នន័យកត់ត្រានៅក្នុងបញ្ជីអ្នកបោះឆ្នោត ឆ្នាំ២០១១ (ឈ្មោះរបស់ពួកគេមិនអាចរកឃើញ ឬមានការផ្លាស់ប្តូរឈ្មោះ) តួលេខនេះគឺ មានកំរិតទាបជាង ១៨.៥% ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឆ្នាំ២០០៨។ ទោះបីជាយ៉ាងណា អ្នកចុះឈ្មោះបោះឆ្នោតប្រមាណ ១,៥ លាននាក់ អ្នកចុះឈ្មោះខ្លះអាចទំនងជានឹងបាត់បង់សិទ្ធិដើម្បីបោះឆ្នោតនៅពេលបោះឆ្នោតខាងមុខ។




រូបថ្លុក ខុមហ្វ្រែល បរិយាយបរិយាកាសនៃការចុះឈ្មោះបោះឆ្នោត

## មជ្ឈមណ្ឌលព័ត៌មានបោះឆ្នោតខុមហ្វ្រែល

គេហទំព័រ : www.comfrel.org ; ទូរស័ព្ទ : 012-43-34-37 ឬ 016-54-43-98 ;
ហ្វេសប៊ុក : www.facebook.com/comfrel.org ; ទ្វីតធ័រ : twitter.com/COMFREL
យូធូប : www.youtube.com/user/comfrel ; Ustream : www.ustream.tv/channel/comfrel

**វិទ្យុសម្លេងសង្គមស៊ីវិល** ៖ មានគោលបំណង ប្រមូលផ្តុំមតិ យោបល់ ទស្សនៈ ការវិភាគ ការសង្កេតឃ្លាំមើល និងផ្តល់ព័ត៌មាននានា ក្នុងការចូលរួមស្ថាបនាសង្គម។ កម្មវិធីនេះ ជាកិច្ចសហការណ៍រវាង ខុមហ្វ្រែល ជាមួយ អង្គការសង្គមស៊ីវិល សមាគមមួយចំនួននៅកម្ពុជា រួមមាន ១-សម្លេងម្ចាស់ឆ្នោត ២-កម្មវិធី សិទ្ធិមនុស្ស ៣-ស្ត្រីអាចធ្វើបាន ៤-សម្លេងកម្មករ/កសិករ ៥-ឃ្លាំមើលប្រចាំសប្តាហ៍ ៦-ទៅ ឬមិនទៅ ៧-សម្លេងពលរដ្ឋអាស៊ាន ៨-សម្លេងជនពិការ។ មានផ្សាយផ្ទាល់រៀងរាល់ថ្ងៃច័ន្ទ ដល់ថ្ងៃអាទិត្យ វេលាម៉ោង ៧.៣០នាទី ព្រឹក ដល់ម៉ោង ៨.៣០នាទីព្រឹក តាមរយៈវិទ្យុ FM105 MHz ឬ www.comfrel.org/voc

...របស់ គ.ជ.ប។ គណបក្សដែលលើកបញ្ហានេះរួមមាន គណបក្សខ្មែរឈប់ក្រ គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សសិទ្ធិមនុស្ស។

» ភាពយឺតយ៉ាវ លំបាក និងរើសអើងក្នុងការសុំលិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់។ គណបក្សដែលលើកបញ្ហានេះរួមមានគណបក្សខ្មែរឈប់ក្រ និងគណបក្សសិទ្ធិមនុស្ស។

» រយៈពេលក្នុងការទទួលពាក្យខ្លីពេក។ គណបក្សដែលលើកបញ្ហានេះរួមមាន និងគណបក្សប្រជាធិបតេយ្យ គណបក្សខ្មែរឈប់ក្រ។

» ពិបាកក្នុងការស្វែងរកបេក្ខជនឈរឈ្មោះ ព្រោះមានការគំរាមកំហែងដោយសម្ងាត់ និងដោយចំហ និងការបំភិតបំភ័យពីអាជ្ញាធរមូលដ្ឋាន ដែលនាំឲ្យបេក្ខជនមួយចំនួនសុំដកឈ្មោះចេញពីបញ្ជីវិញ។ គណបក្សដែលលើកបញ្ហានេះរួមមាន គណបក្សខ្មែរឈប់ក្រ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (ប្រមាណ២០% នៃឃុំ/សង្កាត់ដែលខ្លួនដាក់បេក្ខជន) គណបក្សសញ្ជាតិកម្ពុជា និងគណបក្សសិទ្ធិមនុស្ស។

» យ៉ាងហោចណាស់មានបេក្ខជនឈរឈ្មោះរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានលើកឡើងពីករណីរកឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះបោះឆ្នោតមិនឃើញ និងមានខុសអក្ខរាវិរុទ្ធ។

» បេក្ខជនមួយចំនួនត្រូវបានគណបក្សផ្សេងទិញទឹកចិត្ត និងអូសទាញយក ដែលនាំឲ្យពួកគេសុំដកឈ្មោះចេញពីបញ្ជីបេក្ខជនវិញ។ គណបក្សដែលលើកបញ្ហានេះរួមមាន គណបក្សនរោត្តមរណឫទ្ធិ និងគណបក្សសមរង្ស៊ី។

» យ៉ាងហោចណាស់ក៏មានគណបក្សសមរង្ស៊ីបានលើកឡើងពីការយកឈ្មោះរបស់បេក្ខជនគណបក្សខ្លួនទៅឈរឈ្មោះសម្រាប់គណបក្សមួយចំនួនទៀត និងលើកឡើងថាគ្មានតម្លាភាព ព្រោះមិនមានអ្នកត្រួតពិនិត្យទៅលើការអនុវត្តការងាររបស់ គឃ/សប។


**សម្រាប់ព័ត៌មានបន្ថែមអំពីរបាយការណ៍សង្ខេបសូមទាក់ទង**

»លោក **គល់ បញ្ញា**, នាយកប្រតិបត្តិខុមហ្វ្រែល, ទូរស័ព្ទ ៖ ០១២ ៩៤២ ០១៧, អ៊ីម៉ែល៖ kpanha@comfrel.org

»កញ្ញា **គង់ រ៉ាវីន**, អ្នកសម្របសម្រួលផ្នែកអង្កេតស្ថីទីខុមហ្វ្រែល, ទូរស័ព្ទ ៖ ០១២ ៦៥៤ ៩៥០, អ៊ីម៉ែល៖ ravine@comfrel.org


## សកម្មភាពលេចធ្លោរបស់ខុមហ្វ្រែល

**ព្រឹត្តិបត្រអ្នកឃ្លាំមើល** ៖ បណ្ណាសារព័ត៌មានបោះឆ្នោតតែមួយគត់នៅប្រទេសកម្ពុជាដែលបានចងក្រងព័ត៌មានលម្អិតទាក់ទងនឹងដំណើរការបោះឆ្នោតនៅកម្ពុជា វិភាគព្រឹត្តិការណ៍ និងអនុសាសន៍ផ្សេងៗជុំវិញការបោះឆ្នោត។ ផលិតនៅរៀងរាល់ ៣ខែម្តង ហើយធ្វើការចែកចាយដោយមិនគិតថ្លៃដល់ស្ថាប័នរដ្ឋាភិបាល រដ្ឋសភា អង្គការក្រៅរដ្ឋាភិបាល និស្សិត និងម្ចាស់ឆ្នោត។

**អង្កេតការណ៍ និងសង្កេតការណ៍បោះឆ្នោត** ៖ ខុមហ្វ្រែល ដាក់អ្នកសង្កេតការណ៍បោះឆ្នោតរយៈពេលវែង ចំនួន ២៥០នាក់ និងអ្នកសង្កេតការណ៍រយៈពេលខ្លី ចន្លោះពី ៥០០០នាក់ ទៅ ១០.០០០ នាក់ ក្នុងពេលបោះឆ្នោតនិមួយៗ ដើម្បីរួមចំណែកជម្រុញឱ្យការបោះឆ្នោតមួយមាន តម្លាភាព សេរី និងយុត្តិធម៌ ជាពិសេសការទុកចិត្តពីអ្នកបោះឆ្នោត។ មានកម្មវិធីអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយ ការប្រើប្រាស់ធនធានរដ្ឋ និងហិរញ្ញវត្ថុពេលឃោសនាបោះឆ្នោត របស់គណបក្សនយោបាយ សង្កេត និងប្រមូលព័ត៌មាន និងលទ្ធផលបោះឆ្នោតរហ័ស (Parallel Voter Tabulation Quick Count—PVT) សិក្សាស្រាវជ្រាវអំពី អ្នកអត់បានបោះឆ្នោត (Rapid Survey Related Voter Did Not Vote)។

**សិក្ខាសាលាសម្លេងម្ចាស់ឆ្នោត** ៖ ផ្សព្វផ្សាយ និងផ្តល់របាយការណ៍ស្តីពី ការរីកចំរើន ការអនុវត្ត និងការឆ្លើយតបរបស់មន្ត្រីជាប់ឆ្នោតលើតម្រូវការអាទិភាពនៅបណ្តាមណ្ឌល ឬឃុំ/សង្កាត់នីមួយៗដែលបានរៀបចំសិក្ខាសាលា ឬវេទិកា។ ផ្តល់វេទិកាដល់ពលរដ្ឋចូលរួមតាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីលទ្ធផលការងាររបស់មន្ត្រីជាប់ឆ្នោត ជាពិសេសតម្រូវការអាទិភាពទាំង៥ តាមឃុំនីមួយៗ។

**ប្រវត្តិសង្ខេបតំណាងរាស្ត្រ** ៖ ផ្តល់ព័ត៌មានប្រវត្តិសង្ខេប និងព័ត៌មានទំនាក់ទំនងជាមួយតំណាងរាស្ត្រ ដើម្បីចែកផ្សាយដល់ សហគមន៍ អង្គការ ស្ថាប័នរដ្ឋ ប្រជាពលរដ្ឋ នឹងជួយបង្កើនការយល់ដឹងកាន់តែធំធេងសម្រាប់ម្ចាស់ឆ្នោត និងជាស្ពាន ទំនាក់ទំនងរវាងអ្នកតំណាងរាស្ត្រជាមួយនឹងប្រជាពលរដ្ឋ។



រូបថ្លុក ឧមប្រៀល បរិយាយរបៀបរៀបចំសេចក្ដីព្រាងច្បាប់នៅរដ្ឋសភាកម្ពុជាកន្លងមក មិនបានបើកចំហរដើម្បីឱ្យមានការពិភាក្សាដេញដោលគ្រប់គ្រាន់ និងត្រឹមត្រូវ

# សេចក្ដីព្រាងច្បាប់ សេចក្ដីស្នើច្បាប់ និង សំលេងអនុម័តដែលរដ្ឋសភាបានអនុម័ត និងពិភាក្សាក្នុងសម័យប្រជុំលើកទី៧

តារាងខាងក្រោមពន្យល់ថា រដ្ឋសភាបានពិភាក្សា និងអនុម័តលើសេចក្ដីព្រាងច្បាប់ចំនួន៨ច្បាប់ និងការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ ការតែងតាំងការសំរួលសមាសភាពរាជរដ្ឋាភិបាល និងការជ្រើសតាំងសមាជិកគណៈកម្មការ។

ដំណើការពិភាក្សា និងការអនុវត្តលើសេចក្ដីព្រាងច្បាប់ថវិកាជាតិ និងការដកអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រ មានភាពចំរូងចំរាស់វាទប្បដិវាទយ៉ាងខ្លាំង។ ខាងក្រោមនេះជាឧទាហរណ៍នៃភាពចំរូងចំរាស់ក្នុងការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ថវិការជាតិ (ឬសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងថវិកា២០១២)។

| ល.រ | ថ្ងៃខែ អនុម័ត | សេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ | ចំនួនពេលនៃការ ពិភាក្សា និង អនុម័ត | សំលេង អនុម័ត |
|---|---|---|---|---|
| ១ | ១៤ តុលា | -ការបោះឆ្នោត៖<br>១-ទុកចិត្តលើការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលចំនួន ១រូប<br>២-ទុកចិត្តលើការតែងតាំងអគ្គសវនករចំនួន១រូប និងអគ្គសវនកររងចំនួន២រូប នៃអាជ្ញាធរសវនកម្មជាតិ | ១ ព្រឹក | ១០១/១០៩<br>៨៨/១០៩ |
| ២ | ១៧ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនខេមបូឌា អ៊ិនធើណេស្សូណល អ៊ិនវេស្តមែន ឌីវើឡុបមែនគ្រុប | ១ ព្រឹក | ៧១/៨៩ |
| ៣ | ៤ តុលា | -ការពិភាក្សា និងអនុមត័សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងអាស៊ីតខ្លាំង | ២ ព្រឹក | ៨១/៨៥ |
| ៤ | ៧ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីពន្ធនាគារ | ២ ព្រឹក | ៩៤/៩៦ |
| ៥ | ២៤ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង ឆ្នាំ២០១២ | ១ ព្រឹក | ៨៦/៨៦ |
| ៦ | ២៥ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន | ១ ព្រឹក | ៧៨/៧៩ |
| ៧ | ២៥ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្ដីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ | ១ ព្រឹក | ៧៨/៧៨ |
| ៨ | ២០ តុលា | -ការអនុម័តលើកអភ័យឯកសិទ្ធិសភារបស់ឯកឧត្តម **ចាន់ ចេង** សមាជិកសភា មណ្ឌលខេត្តកណ្ដាល | ១ ព្រឹក | ៨៨/៩៧ |
| ៩ | ២០ តុលា | -ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **ម៉ែន កួន** ជាសមាជិកគណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិ ការអន្តរជាតិ ឃោសនាការ និងព័ត៌មាន | ១ ព្រឹក | ៨៧/៨៧ |
| ១០ | ២១ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម | ២ ព្រឹក | ៧៩/៨០ |
| ១១ | ២១ តុលា | -ការពិភាក្សា និងអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីការកំនត់ចំនួនអសនៈរបស់រដ្ឋសភានៅនីតិកាលទី៥ | ១ ព្រឹក | ៧៦/៧៩ |


## ការផ្សាយសម្លេងសង្គមស៊ីវិល

»»ផ្សាយផ្ទាល់រាល់ថ្ងៃច័ន្ទ ដល់ ថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧. ៣០ នាទី— ៨.៣០ នាទីព្រឹក »»តាមរយៈវិទ្យុ FM 105 MHz (ភ្នំពេញ)

»»ចូលរួមមតិយោបល់ ៖ 023 88 57 45, 016 54 43 98, 012 43 34 37 »»ផ្ញើសារជាអក្សរ (SMS) ៖ 017 91 92 80

»»អ៊ីម៉ែល ៖ comfrel@online.com.kh

»»គេហទំព័រ ៖ www.comfrel.org/voc ឬ www.facebook.com/voc.org

# ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ

តាមទិន្នន័យខុមហ្វ្រែលដែលទទួលបានបង្ហាញថា ក្នុងរយៈពេល៣ខែនេះ (តុលា ដល់ធ្នូ ២០១១) ដែលជាពេលដែលអ្នកតំណាងរាស្ត្រកំពុងមមាញឹកនឹងអនុម័តសេចក្តីព្រាងច្បាប់ផ្សេងៗនោះ ចំនួននៃការចុះមូលដ្ឋានរបស់តំណាងរាស្ត្រមានចំនួន ថយចុះជាងត្រីមាសមុន (កក្កដា-កញ្ញា ២០១១ ជាពេលចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ)។

ក្នុងរយៈពេលនេះ មានអ្នកតំណាងរាស្ត្រយ៉ាងតិច៦៣រូប (ឬ៥១% នៃអ្នកតំណាងរាស្ត្រសរុប១២៣រូប) បានចុះមូលដ្ឋានសរុបបានយ៉ាងតិច ៤២៧លើក គឺតិចជាងរយៈពេល៣ខែមុនប្រមាណ១៨% (ពីខែកក្កដា ដល់កញ្ញា២០១១ អ្នកតំណាងរាស្ត្រចុះមូលដ្ឋានបានសរុប ៥១៩លើក)។

ទោះបីយ៉ាងណា ខុមហ្វ្រែលមិនបានទទួលព័ត៌មានពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅក្នុងមណ្ឌលចំនួន៤ គឺមណ្ឌលកែប មណ្ឌលកោះកុង មណ្ឌលប៉ៃលិន និងមណ្ឌលមណ្ឌលគីរី នោះទេ។

***តារាងទី២៖ ភាគរយកំណើននៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សចន្លោះពីខែតុលា-ធ្នូ ២០១១ ធៀបនឹង ខែកក្កដា-កញ្ញា ២០១១***




បើគិតជាចំនួនចុះមូលដ្ឋានសរុបតាមគណបក្សតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា និងអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋានច្រើនជាងគេ។

ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សទាំង៣រូប ក៏បានបង្កើនការចុះមូលដ្ឋានរបស់ខ្លួនរហូតដល់ ១៤៩លើក គឺកើនឡើងប្រមាណ៤% ធៀបនឹង៣ខែមុន (ពីកក្កដាដល់កញ្ញា ឆ្នាំ២០១១ អ្នកតំណាងរាស្ត្រមកពីគណបក្សសិទ្ធិមនុស្ស បានចុះមូលដ្ឋានចំនួន១៤៣លើក)។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានថយចុះតិចតួចគឺដល់១២% ដែលមានចំនួន២០៨លើក ក្នុងត្រីមាសនេះ គឺតិចជាងត្រីមាសមុនដែលអ្នកតំណាងរាស្ត្រគណបក្សនេះចុះមូលដ្ឋានបាន ២៣៧លើក និងចំនួនតំណាងរាស្ត្របានថយពី៥៥ រូបដល់៤៦រូបផងដែរ។

ការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានការថយចុះច្រើនជាងក្នុងត្រីមាសមុនគឺថយ៤១% ដែលមានចំនួន១១៧លើក នៅត្រីមាសមុនមកត្រឹមតែ៦៩លើក ក្នុងត្រីមាសនេះ។

អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិបានចុះមូលដ្ឋាន ១ដង (ដែលត្រីមាសមុនចុះបាន២លើក) ។

ក្នុងចំណោមតំណាងរាស្ត្រទាំង៦៣រូប ដែលបានចុះមូលដ្ឋាន មានតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាសរុប ៤៦រូប (ស្មើនឹង៥១%នៃតំណាងរាស្ត្រគណបក្សនេះសរុប៩០រូប)។ តំណាងរាស្ត្រគណបក្សសមរង្ស៊ីសរុប១៣រូប (ស្មើនឹង៥០%នៃតំណាងរាស្ត្រគណបក្សនេះសរុប២៦រូប)។ ចំណែកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សចំនួន៣រូប បានចុះមូលដ្ឋានទាំងអស់ និងតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិ ១រូប បានចុះមូលដ្ឋានស្មើនឹង (៥០%នៃតំណាងរាស្ត្រសរុបក្នុងគណបក្ស២រូប) ។

ទោះបីយ៉ាងណា បើគិតជាមធ្យមនៃតំណាងរាស្ត្រម្នាក់ៗដែលចុះមូលដ្ឋានតាមគណបក្សវិញឃើញថា តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សជាមធ្យមចុះបានច្រើនជាងគេ ដោយក្នុងតំណាងរាស្ត្រមួយរូបចុះមូលដ្ឋានជាមធ្យមបាន៥០លើក តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាជាមធ្យមបាន៥លើក តំណាងរាស្ត្រគណបក្សសមរង្ស៊ីជាមធ្យមម្នាក់បាន៥លើក និងគណបក្សនរោត្តមរណឫទ្ធិ១រូប បាន១លើក។

***តារាងទី៣៖ ភាគរយចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្សនយោបាយធៀបភាគរយនៃអាសនៈសភាសរុបតាមគណបក្ស***




បើគិតតាមសមាមាត្រភាគរយនៃតំណាងរាស្ត្រក្នុងរដ្ឋសភាតាមគណបក្ស និងភាគរយនៃការចុះមូលដ្ឋានសរុបតាមគណបក្សបង្ហាញថា ចំនួនចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គណបក្សសិទ្ធិមនុស្សដែលមានអាសនៈប្រមាណ៣% បានចុះមូលដ្ឋានបានប្រមាណ៣៤% ស្មើនឹងជិត ១២ដង នៃចំនួនអាសនៈសរុបរបស់គណបក្សនេះ។ ចំណែកអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ដែលមានអាសនៈ២១% នៅក្នុងរដ្ឋសភាបានចុះមូលដ្ឋានប្រមាណ១៦%។

ចំណែកអ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឫទ្ធិគឺ ស្ទើរតែសមាមាត្រទៅនឹងអាសនៈរដ្ឋសភាដែលគណបក្សនីមួយៗទទួលបានក្នុងរដ្ឋសភាដែលរួមគ្នាមានអាសនៈ១.៥% ក្នុងរដ្ឋសភាក៏ចុះមូលដ្ឋានបាន១% ដែរ។ គណបក្សប្រជាជនកម្ពុជាដែលមានអាសនៈសរុប៧៣% នៅរដ្ឋសភាចុះមូលដ្ឋានបានតែ៤៩% នៃការចុះមូលដ្ឋានសរុបដែលចំនួននេះគឺស្មើនឹងជាងពាក់កណ្តាលនៃចំនួនអាសនៈរបស់គណបក្សនេះក្នុងរដ្ឋសភាប៉ុណ្ណោះ។

តទៅទំព័រ ១៩

### តារាងទី៤៖ គោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគណបក្ស

| គោលបំណងនៃការចុះមូលដ្ឋានទាំង ៤២៧លើករបស់តំណាងរាស្ត្រទាំង៦៣រូប | គណបក្សនយោបាយ | | | | |
|---|---|---|---|---|---|
| | ៤៦រូប | ១៣ រូប | ៣ រូប | ១ រូប | សរុបគោលបំណង |
| សាកសួរសុខទុក្ខចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា | ១៣៥ (៦៥%) | ៣៦ (៥២%) | ១១៧ (៧៩%) | ១ (១០០%) | ២៨៩ (៦៧%) |
| ការចុះពង្រឹងផ្ទៃក្នុងនិងបណ្តាញគណបក្ស | ៤១ (២០%) | ២៩ (៤២%) | ៣១(២១%) | 0 | ១០១ (២៤%) |
| ការចុះអមដំណើរជាក្រុមឬអមដំណើរថ្នាក់ដឹកនាំ | ២៨ (១៣%) | 0 | 0 | 0 | ២៨ (៦%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៤ (២%) | ២(៣%) | ១(១%) | 0 | ៧ (២%) |
| ការអន្តរាគមន៍និងដោះស្រាយបញ្ហានានា | 0 | ២(៣%) | 0 | 0 | ២ (១%) |
| **សរុបគោលបំណងតាមគណបក្ស** | **២០៨** | **៦៩** | **១៤៩** | **១** | **៤២៧ (១០០%)** |

តារាងទី៤បានបង្ហាញថា ការចុះមូលដ្ឋានភាគច្រើនរបស់អ្នកតំណាងរាស្ត្រគឺផ្តោតទៅលើគោលបំណងសាកសួរសុខទុក្ខចែកអំណោយ និងការសម្ពោធសមិទ្ធផលនានាដែលសរុបមានរហូតដល់២៨៩លើក (ឬ៦៧%នៃការចុះមូលដ្ឋានសរុប) ដែលមានការកើនឡើងជាងរយៈពេល៣ខែមុន ព្រោះតែជាពេលកៀកនឹងការបោះឆ្នោតព្រឹទ្ធសភា នៅដើមខែមករា ឆ្នាំ២០១២ និងឃុំសង្កាត់២០១២ខាងមុខនេះ ដែលគណបក្សត្រូវចុះជួបប្រជាជនដើម្បីបង្កើនប្រជាប្រិយភាពរបស់ពួកគាត់។ ការចុះអមដំណើរថ្នាក់ដឹកនាំ៦% ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមាន ២៤%។ ដោយឡែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រក្នុងគោលបំណងចូលរួមវេទិកា ឬសិក្ខាសាលាសាធារណៈមានតិចតួចប៉ុណ្ណោះសរុបបាន ៧លើក (២% នៃការចុះមូលដ្ឋានសរុប)។ ចំណែកការចុះអន្តរាគមន៍វិញនៅតែមានតិចតួចនៅឡើយគឺត្រឹម២លើក ស្មើនឹង១%នៃការចុះមូលដ្ឋានសរុប ដែលចំនួននេះបានថយចុះតិចជាងរយៈពេល ៣ខែមុនទៀត បើទោះជាមួយរយៈក្រោយៗនេះកម្ពុជាកំពុងប្រឈមនឹងជំលោះដីធ្លី និងការបណ្តេញចេញប្រជាជនចេញពីលំនៅដ្ឋានអាណាធិបតេយ្យក៏ដោយ។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា (៤៦រូប ចុះបានសរុប ២០៨លើក)៖** ជាសរុបតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា បានចុះមូលដ្ឋានច្រើនជាងគណបក្សផ្សេងៗ។ ក្នុងនោះ៦៥%នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាគឺក្នុងគោលបំណងសួរសុខទុក្ខចែកអំណោយ និងសម្ពោធសមិទ្ធផលនានា(១៣៥លើក) និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួន (១៣%)។

អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាក៏បានចុះមូលដ្ឋានក្នុងគោលបំណងពង្រឹងគណបក្សរបស់ខ្លួនដែលសរុបមាន២០%។ ចំណែកការចុះមូលដ្ឋានក្នុងគោលបំណងចូលរួមវេទិកា និងសិក្ខាសាលាសាធារណៈមាន២% (៤លើក)។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាមានដូចជា៖** អ្នកតំណាងរាស្ត្រ **គួច សំអាន** បានអញ្ជើញចុះចែកអំណោយប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់នៅភូមិកោះនរា ចំនួន៣៥៧គ្រួសារ និងឧបត្ថម្ភថវិកាបន្ថែម ១គ្រួសារ១០០០០រៀល សរុបអស់ថវិកាចំនួន ៣៥៧០០០០រៀល កាលពីថ្ងៃទី១១ខែតុលាឆ្នាំ២០១១។

**ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសមរង្ស៊ី (១៣រូប ចុះសរុបបាន ៦៩លើក)៖** ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រមកពីគណបក្សសមរង្ស៊ីបានសួរសុខទុក្ខ(៥២% ឬ៣៦លើកនៃការចុះមូលដ្ឋានរបស់គណបក្សនេះសរុប) ការពង្រឹងបណ្តាញគណបក្ស (ស្មើនឹង៤២% ឬ២៩លើក) និងការចូលរួមវេទិកាសាធារណៈ(ស្មើនឹង៣%ឬ២លើក) និងការចុះមូលដ្ឋានក្នុងគោលបំណងអន្តរាគមន៍ស្មើគ្នាដែលសរុបរួមមាន៣%(២លើក)។ ចំណែកការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំខាងគណៈកម្មាធិការខុមហ្វ្រែល មិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋាននេះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីមានដូចជា៖** អ្នកតំណាងរាស្ត្រ **តឹមសួរ ភិរិទ្ធិ** នៅមណ្ឌលកំពង់ចាម បាននាំមុខគេក្នុងការចុះមូលដ្ឋានក្នុងចំណោមតំណាងរាស្ត្របានចុះមូលដ្ឋានបានចុះចំនួន១២ដង កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១១ បានចុះជួបកម្មកររោងចក្រ អឹម និង វ៉េ ប្រមាណជាង ២០០០នាក់ដែលបានធ្វើកូដកម្ម ទាមទារអោយរោងចក្របន្តការងារដល់ក្រុមសហជីប ដែលរោងចក្របានបញ្ឈប់ដោយសារការរើសអើង និងទាមទារសុំឲ្យរោងចក្រទទួលយកនូវសេចក្តីស្នើសុំ៧ចំនុចទៀត ដែលជាលក្ខខណ្ឌសំរួលដល់កម្មករ។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស (៣រូប ចុះបានសរុប ១៤៩លើក)៖** តំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សបានផ្តោតលើចុះសួរសុខទុក្ខចែកអំណោយដែលមានដល់ទៅ៧៩% (១១៧លើក) នៃការចុះមូលដ្ឋានសរុបរបស់គណបក្សនេះ។ ការចុះពង្រឹងគណបក្សមាន២១% (៣១លើក) និងចូលរួមជាវាគ្មិននៅវេទិកាសាធារណៈ១% (១លើក)។

គណៈកម្មាធិការខុមហ្វ្រែលមិនបានទទួលព័ត៌មានទាក់ទងនឹងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សក្នុងគោលបំណងជួយអន្តរាគមន៍បញ្ហារបស់ប្រជាពលរដ្ឋ និងក្នុងគោលបំណងអមដំណើរថ្នាក់ដឹកនាំរបស់ខ្លួននោះទេ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្សមានដូចជា៖** អ្នកតំណាងរាស្ត្រ **កឹម សុខា** មកពីមណ្ឌលកំពង់ចាម បាននាំមុខគេក្នុងការចុះមូលដ្ឋានក្នុងចំណោមតំណាងរាស្ត្របានចុះមូលដ្ឋាន និងក្នុងបក្សរបស់ខ្លួនបានចុះចំនួន៧១ដង។ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អញ្ជើញចូលរួមប្រជុំនៅឃុំកំពង់ប្រាំងស្រុកពារាំង គោលបំណងសំណេះសំណាល និងសួរសុខទុក្ខភ្ញៀវចូលរួមប្រហែល៥០០នាក់។

**-ការចុះមូលដ្ឋានរបស់តំណាងរាស្ត្រគណបក្សនរោត្តមរណឬទ្ធិ (១រូប ចុះបាន១លើក)៖** ខុមហ្វ្រែលទទួលបានព័ត៌មានតែការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសរុប១លើកក្នុងគោលបំណងចុះសួរសុខទុក្ខប្រជាជន(១លើក) ។

**ករណីខ្លះៗនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រគណបក្សនរោត្តមរណឬទ្ធិមានដូចជា៖** អ្នកតំណាងរាស្ត្រ **សៅ រ៉ានី** បានអញ្ជើញសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋមានភ្ញៀវចូលរួម៦០០នាក់ក្នុងនោះមានចែកសោហ៊ុយបន្តិចបន្តួចផងនៅឃុំស្វាយអន្ទរស្រុកស្វាយអន្ទរខេត្តព្រៃវែង កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១១។

# កំសាន្ត



## ដើម្បីសុវត្ថិភាពចរាចរ

កំពុងតែបើកម៉ូតូមកដល់ផ្លូវបំបែកចូលវាលស្រែ នាយ ចូច បង្អង់ម៉ូតូ ហើយឈប់មួយសន្ទុះ...

នាយ ប្លយ ៖ ម៉េចឈប់ម៉ូតូធ្វើអី ?

នាយ ចូច ៖ អញកំពុងតែគិតថា អញត្រូវបង្ខំចិត្តធ្វើដំណើរកាត់វាលស្រែ...

នាយ ប្លយ ៖ ចុះផ្លូវល្អមានម៉េចមិនទៅ ? ផ្លូវកាត់វាលស្រែហ្នឹងដូចជា ស្ងាត់ណាស់ណា ឯងមិនខ្លាចចោរទេអី ?

នាយ ចូច ៖ ប្រថុយម្តងទៅវ៉ើយ លោកចោរ យូរៗអាចជួបតែម្តងទេ តែបើប៉ូលីសចរាចរនៅយាមប៉ុស្តិ៍ខាងមុខនោះវិញ ជួបរាល់ថ្ងៃ ! មុខអាដែលៗ...

នាយ ប្លយ ៖ មានមួក មានកញ្ចក់... ឯងនៅខ្លាចប៉ូលីសចរាចរទៀត ?

នាយ ចូច ៖ ជិះគេចឱ្យឆ្ងាយទៅល្អជាង ព្រោះលោកប៉ូលីសអស់ហ្នឹង ថ្ងៃណាទំនេរខ្លាំង ហៅឯង ទាមទារកប័ណ្ណបើកបរម៉ូតូ ដើម្បីផាក លេង...

នាយ ប្លយ ៖ មែនក៏អី ???




## ប្រព័ន្ធវិមជ្ឈការ

នៅក្នុងអង្គប្រជុំគណបក្សថ្នាក់ឃុំមួយ...

ប្រធានបក្សឃុំ ៖ អស់លោកទាំងអស់គ្នា បន្តិចទៀតនេះនឹងមានការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ហើយក៏ជាការអនុវត្តប្រជាធិបតេយ្យតាមបែបប្រព័ន្ធវិមជ្ឈការដែរ...

សមាជិកបក្ស ៖ អ្វីទៅលោកប្រធាន ដែលហៅថា ប្រព័ន្ធវិមជ្ឈការ នោះ ?

ប្រធានបក្សឃុំ ៖ បាទ គឺជាការផ្ទេរអំណាចសម្រេចចិត្ត និងហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍមូលដ្ឋាន ពីថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋានឃុំ សង្កាត់។

សមាជិកបក្ស ៖ អីចឹង បើខ្ញុំជាប់ឆ្នោតនោះ ខ្ញុំមានអំណាចសម្រេចកិច្ចការងារមូលដ្ឋាន តាមតម្រូវការរបស់អ្នកភូមិហើយ ?

ប្រធានបក្សឃុំ ៖ មិនប្រាកដអីចឹងទាំងស្រុងទេ ព្រោះបើចង់ឈរឈ្មោះបោះឆ្នោតត្រូវបង្ហាញពីភក្តីភាពចំពោះបក្សយើងជាមុនសិន...

សមាជិកបក្ស ៖ ទោះបីជាយ៉ាងណា យើងខ្ញុំសូមប្តេជ្ញាចិត្តអនុវត្តតាមការណែនាំរបស់លោកប្រធានបក្សជានិច្ច...

ប្រធានបក្សឃុំ ៖ និយាយអីចឹងបានត្រឹមត្រូវ...

## មនុស្សអព្យាក្រឹត

កូន ៖ ពុក... ខ្ញុំឆ្ងល់ណាស់ ! គេថា មនុស្សអព្យាក្រឹត ហ្នឹងមានន័យយ៉ាងម៉េច ?

ឪពុក ៖ ហ្ន... មនុស្សអព្យាក្រឹត គឺជាមនុស្សដែលមានការគាំទ្រច្បាស់លាស់ ពីអ្នកនយោបាយ និងមន្ត្រីថ្នាក់ខ្ពស់នៃគណបក្សនយោបាយណាមួយ...

កូន ៖ ហ្អា ! ខ្ញុំនៅតែមិនសូវយល់... នៅសាលារៀន លោកគ្រូ បានប្រាប់ថា មនុស្សអព្យាក្រឹត គឺមនុស្សស្ថិតនៅកណ្តាល មានជំហរមិនលម្អៀង...

ឪពុក ៖ កូនឯងត្រូវយល់ មេរៀនក្នុងសាលា វាផ្សេង... ការអនុវត្តក្នុងសង្គមវាផ្សេង... និយមន័យ វាប្រើខុសគ្នាតាមបរិបទសង្គម។ សម័យឥឡូវ មនុស្សអព្យាក្រឹត ត្រូវបានដាក់ឈ្មោះ ដោយអ្នកនយោបាយ អីចឹង មនុស្សអព្យាក្រឹត ទាល់តែមានគណបក្សនយោបាយឈ្នះឆ្នោតគាំទ្រទើបបាន...

កូន ៖ នេះប្រហែលមកពីខ្ញុំមិនទាន់មានបទពិសោធន៍ក្នុងសង្គម...

Google : comfrel
facebook.com/comfrel
twitter.com/COMFREL
comfrel@online.com.kh

សូមចូលរួមចែករំលែករឿងកំប្លែងខ្លី និងរូបភាពប្លែកៗក្នុងព្រឹត្តិបត្រ អ្នកឃ្លាំមើល សម្រាប់លេខបន្តបន្ទាប់...

# វេទិកាកំណាព្យ និងគតិលោក

"មនោគតិ គឺសំខាន់ជាងចំណេះដឹង"

"Imagination is more important than knowledge"—
Albert Einstein



"អ្នកកើតមកដោយគ្មានអ្វីជាប់នឹងខ្លួនទេ តែអ្នកនឹងស្លាប់ទៅវិញជាមួយនឹង ឈ្មោះរបស់អ្នក ដូច្នេះ កុំឱ្យឈ្មោះនោះ គ្រាន់តែជា ពាក្យមួយ ចូរធ្វើវាឱ្យទៅជា ប្រវត្តិសាស្ត្រមួយ"

*"You are born without anything but you die with your name, so don't let that name be just a WORD, make it a HISTORY"* -Adolf Hilter






## រដ្ឋវភរ

(បទក្របចក្រវាឡមេពាក្យ១២ថ្មី)

១. រដូវភរ គរមនុស្សម្នា ជាទំលាប់ ជាប់ប្រចាំ
ភូតមិនសាំ ប្រាំឆ្នាំម្តង ប៉ងតែម្យ៉ាង កាងអំណាច
ចិត្តឃោរឃៅ ទៅជាស្លូត បូតដាក់ស្នេហ៍ ប្រែឈប់កាច ហាក់ខ្លប
ខ្លាច អាចលន់តួ គួរសមណាស់ ច្បាស់ខាងក្រៅ។

២. តែក្នុងចិត្ត ពិតមិនងាយ ទាយល្បិចស្មៀត ឆ្មៀតមិនដឹង
ភ្លេចសញ្ជឹង នឹងចាញ់កល ខ្វល់ពេលក្រោយ សោយសោកសៅ
បើយើងល្ងង់ លង់ល្បិចល្បួង លួងអង្វរ ល្អខាងក្រៅ
យើងពិតក្តៅ ខ្លៅតាមគេ ជេរអ្នួតឫទ្ធិ គិតខុសគូស។

៣ . មួយសន្លឹក នឹកគិតទៅ ត្រូវវិភាគ ជ្រៀកហេតុការណ៍
កុំស្មានណា ថាសប្បាយ កាយសុខសាន្ត បានយូរនុះ
អ្វីក៏ប្រែ កែដូចភ្លៀង ទៀងទាត់គ្មាន ហ៊ានបោកមនុស្ស
គិតមុនគូស នោះមិនខុស ដុះបញ្ហា ណាអន្តរាយ។

៤. អ្នកក្រៅ.ក្នុង កុងកាច់គ្នា ជាទំលាប់ ជាប់ប្រចាំ
គេមិនសាំ ចាំភូតភរ គរផ្តុំខឹង ប្រឹងបកស្រាយ
ល្អម្យ៉ាងម្នាក់ ជាក់មិនងាយ ទាយទឹកចិត្ត ពិតគ្រប់កាយ
តែកុំស្តាយ ណាយឈប់ប្រើ បើក្រុមពួក លក់ក្បាលយើង។

ថ្ងៃចន្ទ័ ទី២៥ ខែតុលា ឆ្នាំ២០១១
កវីខេត្តស្ទឹងត្រែង **លឹម ចំរើន**

## សេរីភាព

បើធ្វើអ្វីមួយ នៅខ្វល់ចិត្តព្រួយ ត្រូវការអនុញ្ញាត
បើមិនសុំទេ មិនបានដាច់ខាត ត្រូវមានបត់បាទ
ទើបអាចធ្វើបាន។
បើយ៉ាងដូច្នេះ សូមជួយរិះត្រិះ គ្រាន់ជាលំអោន
មានសេរីឬ បើឱ្យទើបបាន ខ្ញុំគិតថា គ្មាន
សេរីភាពអ្វីទេ។
ពិតហើយមិនបាន ធ្វើប៉ះពាល់ប្រាណ សិទ្ធិសេរីគេ
រដ្ឋត្រូវការពារ ដោយត្រូវសសេរ ចងជាច្បាប់ច្បេរ
ដាក់ទោសអ្នកឈ្លាន។
តែបើគ្មានច្បាប់ រដ្ឋអាងចងចាប់ ហៅថាបំពាន
សេរីប្រជា ដែលធម្មនុញ្ញមាន រដ្ឋបែបនឹងគ្មាន
សេរីភាពអ្វីឡើយ។

កវី ៖ មេធាវី **សុក សំអឿន**
(១៩ មករា ២០១១)

# តើអ្នកយល់យ៉ាងណាចំពោះព្រឹត្តិបត្រអ្នកឃ្លាំមើល ?

សូមលោកអ្នកចំណាយពេលវេលាត្រឹមមួយនាទី ដើម្បីចូលរួមអភិវឌ្ឍព្រឹត្តិបត្រអ្នកឃ្លាំមើល ឱ្យកាន់តែត្រូវចិត្ត

**ក»តើអ្នកវាយតម្លៃយ៉ាងណាចំពោះអត្ថបទសម្រាប់លេខ ៤៧នេះ ?**

១. ពេញចិត្ត
២. ធម្មតា
៣. គួរកែប្រែ

*ប្រសិនបើ គួរកែប្រែ សូមរៀបរាប់ ៖*

..................................................
..................................................
..................................................

**ខ»តើអ្នកប្រើប្រាស់ព្រឹត្តិបត្រ អ្នកឃ្លាំមើល ក្នុងគោលបំណងអ្វីដែរ ?**

១. ការបោះឆ្នោត/តំណាងរាស្ត្រ
២. កំសាន្ត
៣. ឯកសារយោង

**គ»តើអ្នកធ្លាប់ទទួលបានព្រឹត្តិបត្រ អ្នកឃ្លាំមើល តាមរយៈអ្វី ?**

១. ការចែកជូនជាព្រឹត្តិបត្រ
២. គេហទំព័រ
៣. អ៊ីម៉ែល

**ឃ»តើព័ត៌មាន ឬអត្ថបទប្រភេទណាដែលអ្នកចង់បានពី ព្រឹត្តិបត្រ អ្នកឃ្លាំមើល ?**

១. ព័ត៌មានប្រជាធិបតេយ្យ
២. ច្បាប់ និងបទប្បញ្ញត្តិថ្មីៗ
៣. ផ្សេងៗ (សូមរៀបរាប់) ៖ ....

..................................................
..................................................
.............................................

**ង»តើអ្នកអាចផ្តល់ព័ត៌មានត្រឡប់ខ្លះៗ អំពី អាយុ ទីតាំង និងមុខរបររបស់អ្នកបានដែរ ឬទេ ?**

១. អាយុ ក្រោម ១៨ ឆ្នាំ
២. អាយុពី ១៨ ឆ្នាំ - ២៧ ឆ្នាំ
៣. អាយុលើសពី ២៧ឆ្នាំ
៤. រស់នៅភ្នំពេញ
៥. រស់នៅតាមបណ្តាខេត្ត
៦. ជា សិស្ស/និស្សិត
៧. ជា បុគ្គលិករដ្ឋ/ឯកជន
៨. អត់ទាន់មានការងារធ្វើ
៩. ផ្សេងៗ

(..................................................
..................................................
.........................................)

## គណៈកម្មការព្រឹត្តិបត្រ

| | | |
|---|---|---|
| ១» លោក **គល់ បញ្ញា** | | ទីប្រឹក្សាផ្តល់យោបល់ |
| ២» លោក **ចន្ទ័ ដារិទ្ធ** | | ប្រធានព័ត៌មាន និងការផ្សាយ |
| ៣» លោក **ស្រី សុតត្រ័** | | អ្នកនិពន្ធ និងរចនាទំព័រ |
| ៤» លោក **ជិន សុខុម** | | លេខាការផ្សាយ |
| ៥» លោក **ស្នួង សឿន** | | លេខាការផ្សាយ |
| ៦» កញ្ញា **រិន្ទ បុណ្ណិកា** | | លេខាការផ្សាយ |

**<u>អាសយដ្ឋាន</u>**៖ ផ្ទះលេខ១៣៩ ផ្លូវ.១២១ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ័ ៖ ០២៣ ៨៨៤ ១៥០
ទូរសារ ៖ ០២៣ ៨៨៥ ៧៤៥
អ៊ីម៉ែល ៖ comfrel@online.com.kh
គេហទំព័រ ៖ www.comfrel.org
ប្រអប់សំបុត្រ៖ **១១៤៥**

## សេចក្តីជូនដំណឹង

ព្រឹត្តិបត្រ **អ្នកឃ្លាំមើល** ផលិតឡើង ដើម្បីផ្សព្វផ្សាយព័ត៌មានបោះឆ្នោត បំពេញចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋ និងអ្នកតំណាងរាស្ត្រ ថ្នាក់ដឹកនាំ ដែលពាក់ពន្ធ័ក្នុងការចូលរួមស្ថាបនា និងអភិវឌ្ឍសង្គមប្រជាធិបតេយ្យ។

ប្រសិនបើលោក លោកស្រី អ្នកនាង កញ្ញា មានសំណូមពរ ឬបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រ និងឯកសារផ្សេងៗដែលផលិតដោយ **ខុមហ្វ្រែល** សម្រាប់រក្សាទុក សូមទំនាក់ទំនងមកការិយាល័យខុមហ្វ្រែល ឬចូលមកកាន់ គេហទំព័ររបស់ខុមហ្វ្រែល តាមអាសយដ្ឋានដូចដែលបានផ្តល់ជូននេះ យើងខ្ញុំនឹងដោះស្រាយជូននូវរាល់បញ្ហារបស់លោក អ្នកនាង កញ្ញា ដោយមេត្រីភាព។

សូមអរគុណ !

# តួនាទី និងភារកិច្ចដែលអ្នកសង្កេតការណ៍ត្រូវធ្វើ

